## ១_ការសិក្សាក្នុងព្រះពុទ្ធសាសនា

៙ លោកគ្រូជាម្ចាស់បានសម្តែង នាងខ្ញុំបានស្តាប់មកថា ព្រះសម្មាសម្ពុទ្ធ បានត្រាស់ថា

៙ ម្នាលអ្នកទាំងឡាយ កាលដែលតថាគតនៅជាពោធិសត្វ មិនទាន់បានត្រាស់ដឹងនៅឡើយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សត្វលោកនេះដល់នូវសេចក្តីលំបាកណាស់ តែងតែកើតមកហើយ ក៏ចាស់ ឈឺ ស្លាប់ ថែមទាំងមាននូវសេចក្តីទុក្ខជាប់តាមជានិច្ច ថែមទាំងមិនដឹងច្បាស់អំពីការរលាស់ចោលនូវសេចក្តីទុក្ខ គឺ ជរា និង មរណៈនេះទៀតផង ។ តើកាលណាទៅ ទើបការរលាស់ចោលនូវសេចក្តីទុក្ខនេះ នឹងប្រាកដឡើងបាន ។

៙ ម្នាលអ្នកទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា កាលអ្វីកើតមាន ទើបជរា និងមរណៈ កើតមានព្រោះ អ្វីជាបច្ច័យ ។

៙ ម្នាលអ្នកទាំងឡាយ តថាគតក៏បានត្រាស់ដឹងហើយដោយប្រាជ្ញា ព្រោះយោនិសោមនសិការ ថាកាលបើជាតិកើតមាន ជរា និងមរណៈ ក៏កើតមាន ជរា និងមរណៈកើតមានព្រោះជាតិជាបច្ច័យ ។

ជាតិមានជីវិត គឺ បដិសន្ធិព្រោះកំណើតព្រមជាមួយកងទុក្ខទាំង ៤ កង គឺ ជាតិទុក្ខ ជរាទុក្ខ ព្យាធិទុក្ខ មរណទុក្ខ ។

ការសិក្សាបដិបត្តិធម៌ក្នុងព្រះពុទ្ធសាសនា គឺដើម្បីកំណត់ដឹងនូវទុក្ខ ។

## ២_ជីវិត

៙ ជីវិត គឺ ជាបរមត្ថធម៌ ប្រព្រឹត្តទៅតាមហេតុ តាមបច្ច័យ ។ ដូច្នេះ ជីវិតជាមនុស្ស ជាសត្វ ជាតួខ្លួនពុំមានទេ តែជីវិត គឺ ជារូបធម៌ និងជានាមធម៌ ដែលសម្រេចបានយ៉ាងត្រឹមត្រូវពិតប្រាកដ តាមហេតុបច្ច័យ ដែលបានញ៉ាំងជីវិតឱ្យកើតឡើង ។

❀ ហេតុបច្ច័យនៃជីវិត ពុំមែនជាបុគ្គលណាដែលជាអ្នកដទៃ ឬខ្លួនយើងឡើយ តាមពិតហេតុបច្ច័យនៃជីវិតបច្ចុប្បន្ន គឺ អវិជ្ជា តណ្ហា ឧបាទាន កម្មភព ក្នុងអតីតជាតិ ឯចំណែក ផស្សាហារ [១] ចេតនាវិញ្ញាណ ជាបច្ច័យក្នុងបច្ចុប្បន្នខណៈនៃជីវិត ដូច្នេះការចម្រើនសតិប្បដ្ឋានវិបស្សនា គឺមិនមែនជាការគិតសាងជីវិតខ្លួនឯងឱ្យយ៉ាងនេះ ឬយ៉ាងនោះទេ តែត្រូវផ្ដើមសង្កេតពិនិត្យចំពោះជីវិតក្នុងបច្ចុប្បន្នខណៈឱ្យឃើញដោយបញ្ញា ទៅតាមសេចក្ដីពិតនៃជីវិត រួចហើយបញ្ញាអាចមានកម្លាំងដោយសតិប្បដ្ឋានបដិបត្តិ ឃើញជីវិតរលត់ ឃើញជីវិតបែកធ្លាយ ពុំមែនខ្លួនជាអ្នកស្លាប់ បញ្ញាជាក់ច្បាស់យ៉ាងនេះឯង ដែលអាចនាំសត្វឱ្យបានដល់ទីឋានដែលមិនស្លាប់ ពោល គឺ ព្រះនិព្វាន ។

❀ ព្រះនិព្វាន ជាឈ្មោះនៃការផុតចាកទុក្ខ ។

❀ ការផុតចាកទុក្ខ គឺ ជាព្រះនិព្វាន ។

[១] ផស្សៈ គឺ សភាពដែលប៉ះពាល់ ។

## ៣. ការសិក្សាព្រះអភិធម្ម

❀ ការសិក្សាព្រះអភិធម្ម គឺ ជាការសិក្សាអំពីជីវិតរបស់យើងគ្រប់រូប ថាតើអ្វីដែលជាខ្លួនឯង ។

- *ខ្លួនឯង* គឺ ជារូបធម៌ នាមធម៌ ដែលមិនមែនជាយើង ។

- *អភិធម្ម* គឺ បញ្ញត្ត បញ្ញត្ត គឺជាទុក្ខ ទុក្ខណាៗ ស្មើ ដោយខន្ធ គឺ មិនមានឡើយ ។

- *ខន្ធ* គឺ គ្រាន់តែសម្មត ដែលត្រូវកំណត់ព្រះធម៌បីប្រការ គឺ **អនិច្ចតា១ ទុក្ខតា១ អនត្តតា១**

❀ ធម៌ឯណាដែលមានឈ្មោះថា **អនិច្ចតា** គឺជាភាពដែលប្រែប្រួលមិនទៀងទាត់ ។

❀ ធម៌ឯណាដែលមានឈ្មោះថា **ទុក្ខតា** គឺជាភាពដែលជាទុក្ខ ។

❀ ធម៌ឯណាដែលមានឈ្មោះថា **អនត្តតា** គឺជាភាពមិនមែនជារបស់ខ្លួន ។

* ធម៌ទាំងពួង គឺ បរមត្ថធម៌ ។

*បរមត្ថធម៌មានបួន (៤) គឺ*

ចិត្ត
ចេតសិក
រូប
} ជាអនត្តាមិនមែនតួខ្លួន
និព្វាន

. ចិត្តបរមត្ថ បានដល់ ចិត្ត ៨៩ ឬ ១២១ ដួង

. ចេតសិកបរមត្ថ បានដល់ចេតសិក ៥២ ដួង

. រូបបរមត្ថ បានដល់រូប ២៨

. និព្វានបរមត្ថ បានដល់ព្រះនិព្វាន (គឺមិនកើត មិនរលត់)

. ចិត្តបរមត្ថ
. ចេតសិកបរមត្ថ
. និព្វានបរមត្ថ
} ជានាមធម៌

. ចិត្ត
. ចេតសិក
} ជានាមធម៌ដឹងអារម្មណ៍

. និព្វាន ជាធម៌មិនដឹងអារម្មណ៍

រូប ២៨ ជារូបក្ខន្ធ ខន្ធ គឺជារូបធម៌ នាមធម៌ សង្ខារធម៌ សង្ខតធម៌ គឺជាធម៌ដែលមានបច្ច័យតាក់តែង និងកើតរលត់

. ខន្ធមាន ៥ គឺ រូបក្ខន្ធ១ វេទនាខន្ធ១ សង្ខារក្ខន្ធ១ សញ្ញាខន្ធ១ វិញ្ញាណក្ខន្ធ១ ។

* ខន្ធ ៥ នេះ គឺជាទុក្ខ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ទុក្ខណាៗស្មើដោយខន្ធនេះមិនមាន ។

## ៤. ព្រះពុទ្ធឱវាទ

អតីតំ នាន្វាគមេយ្យ នប្បដិកង្ខេ អនាគតំ
យទតីតម្បហីនន្តំ អប្បត្តញ្ច អនាគតំ ។

បុគ្គលមិនគប្បីអាឡោះអាល័យ នូវខន្ធជាអតីតៈ មិនគប្បីប្រាថ្នានូវខន្ធជាអនាគត ព្រោះថាខន្ធណាដែលជាអតីតៈ ខន្ធនោះកន្លងហួសទៅ ខន្ធណាដែលជាអនាគត ខន្ធនោះក៏មិនទាន់មកដល់ដែរ ។

- ឧបនីយតិ លោកោ អទ្ធុវោ ។ សត្វលោកដែលជរា នាំទៅមិនកាំងនៅយូរ នាំចូលទៅរកមរណៈ ។
- អតាណោ លោកោ អនភិស្សរោ ។ សត្វលោក មិនមានទីពឹងពួន មិនមានឥស្សរៈលើខ្លួនឯង ។
- អស្សកោ លោកោ សព្វំ បហាយគមនីយំ ។ សត្វលោកមិនមានវត្ថុណាជារបស់ខ្លួន ត្រូវលះបង់របស់គ្រប់យ៉ាងហើយទៅ ។
- ឩនោ លោកោ អតិត្តោ តណ្ហា ទាសោ ។ សត្វលោកខ្វះកន្លះជានិច្ចមិនចេះឆ្អែត ជាទាសៈនៃតណ្ហា ។

## ៦-ជំនួយសតិភាគទី ៤

អរហា ចក្ខុំ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ សោតំ ឃានំ ជិវ្ហំ កាយំ រូបេ សទ្ទេ គន្ធេ រសេ ផោដ្ឋព្វេ ធម្មំ វិបាកាព្យាកតេ កិរិយាព្យាកតេ ខន្ធេ អនិច្ចតោ ទុក្ខតោ អនត្តតោ វិបស្សតិ ម

ព្រះអរហន្តរមែងឃើញច្បាស់នូវចក្ខុ ដោយសេចក្តីថា ជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ឃើញច្បាស់នូវសោតៈ ឃានៈ ជិវ្ហា កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ហទយវត្ថុ និង ខន្ធទាំងឡាយ ដែលជាអព្យាកតវិបាក អព្យាកតកិរិយា ដោយសេចក្តីថា មិនទៀង ជាទុក្ខ ជាអនត្តា ។

❀ កាយរូបនេះ កើតឡើងដោយអាស្រ័យសម្ភារផ្សេងៗ មានការចម្រើនធំធាត់ដោយចំណីអាហារ ប៉ុន្តែទោះជាធាត់ ស្អមយ៉ាងណា ក៏ត្រឹមតែមហាភូតរូប ៤ គឺ ដី ទឹក ភ្លើង ខ្យល់ និង ឧបាទាយរូបផ្សេងៗទៀតប៉ុណ្ណោះ ពុំមែនជាសត្វបុគ្គលតួខ្លួនឡើយ ចំណែកវិញ្ញាណរបស់សត្វលោក បានអាស្រ័យនឹងរូបកាយនេះ ព្រោះមានវត្ថុរូបជាទីអាស្រ័យ និងដោយអារម្មណប្បច្ច័យ ទើបមានវិញ្ញាណកើតឡើងបន្តគ្នា ពុំមានវិញ្ញាណណាមួយជាសត្វឡើយ ។

- បុគ្គលគួរពិចារណាអភិធម្ម ក្នុងជីវិតប្រចាំថ្ងៃ ដោយសេចក្តីព្យាយាម អំណត់អត់ធន់ រហូតទាល់តែលះបង់បាននូវការតម្កើងខ្លួន ព្រោះរកខ្លួនមិនឃើញ ។

- បុគ្គលអ្នកសិក្សាព្រះធម៌ គួរជាបុគ្គលព្យាយាម ដោយការបដិបត្តិយ៉ាងត្រឹមត្រូវ គួរជាបុគ្គលមាននូវការសង្រួមកាយ វាចា ចិត្ត មាននូវគុណធម៌ គឺសេចក្តីល្អបរិសុទ្ធ គួរជាបុគ្គលមាននូវធម៌៥ប្រការ ដែលជាកម្លាំងច្បាំងជាមួយសត្រូវក្នុងខ្លួន គឺ :

១.សទ្ធាពលៈ កម្លាំង គឺការជឿចំពោះសេចក្តីពិត ។

២.វិរិយពលៈ កម្លាំង គឺការព្យាយាមកម្ចាត់បាប ចម្រើនបុណ្យ ។

៣.សតិពលៈ កម្លាំង គឺស្មារតីភ្ញាក់រលឹកដឹងទាន់ និងយល់អំពីការពិត ។

៤.សមាធិពលៈ កម្លាំង គឺចិត្តស្ងប់ដោយប្រពៃ ។

៥.បញ្ញាពលៈ កម្លាំង គឺការដឹងហេតុផលពិត ។

បុគ្គលគួរជាអ្នកដឹងច្បាស់នូវអរិយសច្ចៈ ព្រះពុទ្ធកិច្ចក្នុងវស្សាទី៤៥ ជាវស្សាចុងក្រោយ ព្រះពុទ្ធដំណើរមុនបរិនិព្វាន ក្នុងវេលាព្រឹកព្រាង ព្រះមានព្រះភាគ ទ្រង់យាងចូលទៅបិណ្ឌបាត ក្នុងក្រុងវេសាលី ជាគ្រាចុងក្រោយ រួចហើយព្រះសាស្តា ទ្រង់យាងទៅកាន់ភណ្ឌគ្រាម ជាផ្លូវធ្វើពុទ្ធដំណើរទៅកាន់កុសិនារា ដែលជាកន្លែងបរិនិព្វាន ។

ក្នុងខណៈដែលព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងស្រុកភណ្ឌគ្រាម ព្រះសាស្តាទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រោះតែមិនដឹងច្បាស់នូវអរិយធម៌៤ប្រការ ទើបតថាគត និងពួកអ្នក ត្រាច់រង្គាត់ទៅអស់កាលយូរយ៉ាងនេះ ឥឡូវនេះ តថាគតបានដឹងច្បាស់នូវសីល សមាធិ បញ្ញា និង វិមុត្តិ ដែលជាអរិយៈ ហើយតណ្ហាដែលទៅកាន់ភពអស់ហើយ ឥឡូវនេះភពថ្មីមិនមានទៀតឡើយ។

ព្រះដ៏មានព្រះភាគ ទ្រង់តែងតែត្រាស់សម្តែង ម្នាលអ្នកទាំងឡាយ ចូរឃើញភ័យព្រោះការមិនដឹង គឺព្រោះតែការមិនដឹង ទើបអ្នកទាំងឡាយ តែងមាននូវសេចក្តីប្រមាទ

ក៏ព្រោះតែការមិនដឹង ទើបអ្នកទាំងឡាយមាននូវសេចក្តីទុក្ខ ទុក្ខជួនលើទុក្ខ ព្រោះតែការមិនដឹង ។

ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរភ្ញាក់ឡើង ព្រោះតែការលង់លក់ ព្រោះតែការមិនដឹង ទើបតថាគត និងពួកអ្នកត្រាច់រង្គាត់អស់កាលយូរ តែឥឡូវតថាគតបានធ្វើនូវទីពឹងឱ្យដល់ខ្លួនឯង បានដល់ទីបំផុតនៃទុក្ខ គោលគឺព្រះនិព្វាន ភពថ្មីមិនមានទៀតឡើយ ។

ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរភ្ញាក់ឡើង ហើយដើរមកតាមផ្លូវដែលតថាគតទុកនូវស្នាមឱ្យពួកអ្នក ។

❀ លោកគ្រូជាម្ចាស់បានសម្តែង ព្រះតថាគតមានព្រះឱវាទ ម្នាលអ្នកទាំងឡាយ អំណើះអត់ពីតថាគតទៅ ព្រះធម៌គង់នៅ គឺជាតថាគតហើយ ក៏គឺព្រះធម៌នេះហើយ ដែលអាចនាំអ្នកទាំងឡាយឱ្យបានទៅដល់ព្រះនិព្វាន ក៏គឺព្រះធម៌នេះហើយ ដែលអាចជួយឱ្យសត្វលោក គឺ អ្នកទាំង-ឡាយបានសេចក្តីសុខពិត គឺសេចក្តីសុខតាមផ្លូវចិត្ត សុខព្រោះស្ងប់ សុខព្រោះអស់ទុក្ខ សុខព្រោះមាននូវព្រះធម៌



ជាទីពឹង សុខព្រោះមានខ្លួនឯងជាទីពឹង ( អត្តា ហិ អត្តនោ នាថោ ) ។

ពាក្យថាមានខ្លួនឯងជាទីពឹងក្នុងទីនេះ គឺមានតែខ្លួនឯងទេ ដែលអាចជួយសម្អាតចិត្តឱ្យខ្លួនឯងបាន មានតែខ្លួនឯងទេ ដែលអាចរំលត់កិលេសឱ្យខ្លួនឯងបាន មានតែខ្លួនឯងទេ ដែលអាចលះនូវការប្រកាន់ខ្លួន កន្លងបង់សំយោជនៈទាំងអស់បាន ទុក្ខទាំងឡាយរមែងមិនពាល់ត្រូវ មានតែខ្លួនទេ ដែលអាចរក្សាចិត្តរបស់ខ្លួនឯងបាន គឺរក្សាយ៉ាងណាដើម្បីមិនឱ្យធ្លាក់ចូលក្នុងផ្លូវអកុសលក៏យ៉ាងនោះដែរ ដោយមានសតិជាធំក្នុងការគ្រប់គ្រង ឱ្យចិត្តប្រព្រឹត្តទៅក្នុងកុសលជានិច្ច ។

*សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ទំព័រ ៩០*

ព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងអនុបុព្វីកថា ដល់ពួកមហាជន គឺទ្រង់ប្រកាសទានកថា១ សីលកថា១ សគ្គកថា១ ទោសនៃកាមទាំងឡាយដ៏លាមកសៅហ្មង១ អានិសង្សក្នុងបព្វជ្ជា១ ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ពួកមហាជនទាំង

នោះមានចិត្តស្រួល មានចិត្តទន់ មានចិត្តជ្រះថ្លា មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ឡើងក្នុងកាលណា ទ្រង់ក៏ប្រកាសធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច១ សមុទយសច្ច១ និរោធសច្ច១ មគ្គសច្ច១ ( ទាំងនេះ គឺជាអរិយសច្ចៈ ៤ ) ។

ម្នាលអ្នកទាំងឡាយ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែង ធម្មតាធម្មជាតិដែលមានការកើតឡើងនៅខាងដើម ធម្មជាតិទាំងអស់នោះ រមែងមានការរលត់ទៅវិញនៅខាងចុងជាធម្មតា ម្នាលអ្នកទាំងឡាយ ចំពោះបុគ្គលណាដែលបានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានត្រាស់ដឹងអរិយសច្ចធម៌មិនយូរឡើយ ចិត្តនឹងបានរួចស្រឡះចាកអាសវៈទាំងឡាយព្រោះមិនប្រកាន់មាំ ។

❀ ព្រះពុទ្ធទាំងឡាយ តែងត្រាស់ថា ព្រះនិព្វានជាធម៌ដ៏ឧត្តម ។ ការមិនធ្វើអំពើបាបទាំងពួង ការបំពេញកុសល ការញុំាងចិត្តរបស់ខ្លួនឱ្យផូរផង់ទាំង ៣នេះ ជាពាក្យប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ។

❀ ក្នុងសម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅបាដលិគ្រាម គ្រានោះព្រះអង្គទ្រង់ត្រាស់នឹងអ្នកបាដលិគ្រាមថា ម្នាលគហបតីទាំងឡាយ អានិសង្សនៃបុគ្គលមានសីលនៃសីលសម្បទាមាន ៥ប្រការនោះ គឺ បុគ្គលមានសីលដល់ព្រមដោយសីល ក្នុងលោកនេះរមែងមានគំនរទ្រព្យដ៏ធំដែលមានសេចក្តីមិនប្រមាទជាហេតុ នេះជាអានិសង្សទី១ មួយទៀតកិត្តិសព្ទដ៏ពីរោះរបស់បុគ្គលមានសីល ដល់ព្រមដោយសីល តែងផ្សាយទៅសព្វទិស នេះជាអានិសង្សទី២ មួយទៀតបុគ្គលមានសីលដល់ព្រមដោយសីល នោះចូលទៅកាន់បរិស័ទណា គឺខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតិបរិស័ទក្តី សមណបរិស័ទក្តី ជាបុគ្គលមានសេចក្តីក្លៀវក្លា ចូលទៅដោយការមិនអៀនអន់ នេះជាអានិសង្សទី៣ ។ មួយទៀតបុគ្គលមានសីលដល់ព្រមដោយសីល ជាបុគ្គលមិនវង្វេងពេលធ្វើមរណកាល នេះជាអានិសង្សទី៤ ។ មួយទៀតបុគ្គលមានសីលដល់ព្រមដោយសីល លុះបែកធ្លាយរាងកាយ ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងកើតក្នុង

លោក គឺមនុស្ស សុគតិ និងឋានសួគ៌ នេះជាអានិសង្សទី៥។

*សុត្តន្តបិដក មជ្ឈិមនិកាយ ទុតិយភាគ បិដកលេខ ២១*
*ទំព័រ ៦២-៦៣ ការបញ្ញត្តសច្ចៈ ៤ ។*

ម្នាលភិក្ខុទាំងឡាយ ក្នុងកាលពីដើមក្តី ក្នុងកាលឥឡូវក្តី តថាគតតែងបញ្ញត្តនូវទុក្ខផង នូវសេចក្តីរលត់នៃទុក្ខផង ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃ ជេរតម្រាម ប្រទូស្តបៀតបៀនធ្វើបាបតថាគត ក្នុងការប្រកាសសច្ចៈទាំង ៤ នោះ ម្នាលភិក្ខុទាំងឡាយ តថាគតមិនមានសេចក្តីក្រោធ មិនមានសេចក្តីក្រេកអរ គឺទោមនស្ស មិនមានសេចក្តីមិនរីករាយនៃចិត្តក្នុងហេតុមានជេរជាដើមនោះ ។

ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃធ្វើសក្ការៈ គោរពរាប់អានបូជាតថាគត ក្នុងការប្រកាសសច្ចៈនោះម្នាលភិក្ខុ-ទាំងឡាយ តថាគតមិនមានសេចក្តីត្រេកអរ មិនមានសេចក្តីសោមនស្ស មិនមានសេចក្តីពានចិត្ត ក្នុងសក្ការៈគោរពជាដើមនោះទេ ។ ម្នាលភិក្ខុទាំងឡាយ បើពួកជនដទៃធ្វើ



សក្ការៈគោរពរាប់អានបូជាតថាគត ក្នុងការប្រកាសសច្ចៈនោះ ម្នាលភិក្ខុទាំងឡាយ តថាគតមានសេចក្តីត្រិះរិះក្នុងសក្ការៈជាដើមនោះ យ៉ាងនេះថា ខន្ធបញ្ចកៈណាដែលតថាគតបានកំណត់ដឹងក្នុងកាលមុនរួចហើយ សក្ការៈមានសភាពយ៉ាងនេះ គឺពួកជនដទៃធ្វើដល់តថាគត ក៏ចំពោះខន្ធបញ្ចកៈនោះ ។

( ២៥ ) ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនេះបើពួកជនដទៃ ជេរតម្រាម ប្រទូស្តបៀតបៀនធ្វើបាបអ្នកទាំង-ឡាយ អ្នកទាំងឡាយមិនត្រូវធ្វើសេចក្តីក្រោធ មិនត្រូវធ្វើសេចក្តីមិនត្រេកអរ គឺទោមនស្ស មិនត្រូវធ្វើសេចក្តីមិនរីករាយនៃចិត្តក្នុងពាក្យជេរជាដើមនោះឡើយ ។

● ព្រះតថាគតត្រាស់នឹងព្រះអានន្ទ ម្នាលអានន្ទបណ្តាបុគ្គលដែលលុះក្នុងទិដ្ឋិទាំង ៣ ពួកនោះ បុគ្គលណាពោលយ៉ាងនេះថា វេទនាជារបស់បុគ្គលនោះ អ្នកគប្បីពោលតបយ៉ាងនេះថា ម្នាលអាវុសោ វេទនានេះមាន ៣ យ៉ាង គឺសុខវេទនា១ ទុក្ខវេទនា១ អទុក្ខមសុខវេទនា១

បណ្ដាវេទនាទាំងនេះ អ្នកពិចារណាឃើញច្បាស់នូវវេទនាណាថាជាខ្លួន ។ ម្នាលអានន្ទ សុខវេទនាក្ដី ទុក្ខវេទនាក្ដី ជាធម្មជាតិមិនទៀង ជាធម្មជាតិដែលបច្ច័យតាក់តែងកើតឡើង ហើយមានកិរិយាអស់ទៅ វិនាសទៅ រលត់ទៅជាធម្មតា ។ អ្នកទាំងឡាយ គប្បីពិចារណានូវខ្លួនដែលមិនទៀង លាយច្រឡំដោយសុខ និងទុក្ខ មានកិរិយាកើតឡើង និងវិនាសទៅជាធម្មតា។ អ្នកទាំងឡាយ កាលបានពិចារណាយ៉ាងនេះរមែងមិនប្រកាន់នូវធម្មជាតិឯណានីមួយក្នុងលោក (មានខន្ធលោកជាដើម) កាលបើមិនប្រកាន់ហើយ ក៏រមែងមិនតក់ស្លុត កាលបើមិនតក់ស្លុតហើយ រមែងបរិនិព្វានចំពោះខ្លួនឯង តែងដឹងច្បាស់ថា កំណើតរបស់អញអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ កិច្ចដទៃមិនមានទៀតឡើយ ។

❀ ម្នាលអ្នកទាំងឡាយ ហេតុនាំឱ្យកើតបញ្ញាមាន ៣ យ៉ាង គឺ :

១. សុតមយបញ្ញា បញ្ញាកើតពីការស្ដាប់

២. ចិន្តាមយបញ្ញា បញ្ញាកើតពីការគិត

៣. ភាវនាមយបញ្ញា បញ្ញាកើតពីការភាវនា

បញ្ញាទាំងឡាយ នឹងកើតឡើងបានក៏ត្រូវអាស្រ័យបច្ច័យឱ្យកើតដែរ មានការស្ដាប់ជាដើម ។

ការស្ដាប់ ក៏គឺការរៀន ការសិក្សា ហើយប្រយោជន៍នៃការស្ដាប់ធម៌ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃការស្ដាប់ព្រះធម៌មាន ៥ ប្រការ :

១.អ្នកស្ដាប់តែងបានស្ដាប់នូវរឿង ដែលមិនទាន់បានស្ដាប់ ។

២.រឿងណាស្ដាប់ហើយ នៅមិនទាន់យល់ច្បាស់ អាចយល់ច្បាស់ក្នុងរឿងនោះ ។

៣.អាចកម្ចាត់បង់នូវការសង្ស័យបាន ។

៤.ធ្វើឱ្យឃើញតាមសេចក្ដីពិត ។

៥.ចិត្តអ្នកស្ដាប់តែងថ្លាថ្លៃផង ។

ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងការស្តាប់ព្រះធម៌ ៥ ប្រការ យ៉ាងនេះឯង ( អង្គុត្តរនិកាយ បញ្ចកនិបាត ) ។

❀ អ្នកទាំងឡាយគប្បីព្យាយាម ស្តាប់ព្រះធម៌ដោយគោរព ។

❀ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែង ម្នាលភិក្ខុទាំងឡាយ ពួកឧបក្កិលេស គឺសេចក្តីសៅហ្មងនៃចិត្ត តើដូចម្តេច គឺ **អភិជ្ឈាវិសមលោភៈ** ជាឧបក្កិលេសនៃចិត្ត១ **ព្យាបាទ** ជាឧបក្កិលេស១ **កោធៈ** ជាឧបក្កិលេសនៃចិត្ត១ **ឧបនាហៈ** ( ការចងកំហឹងទុក ) ជាឧបក្កិលេស១ **មក្ខៈ** ( ការលុបគុណរបស់អ្នកមានគុណ ) ជាឧបក្កិលេស១ **បឡាសៈ** (ការកាន់យក ឬក៏ប្រៀបផ្ទឹម ឬប្រណាំងភាសា) ជាឧបក្កិលេសនៃចិត្ត១ **ឥស្សា** ( សេចក្តីច្រណែន ) ជាឧបក្កិលេសនៃចិត្ត១ **មច្ឆរិយៈ** ( សេចក្តីកំណាញ់ ) ជាឧបក្កិលេសនៃចិត្ត១ **មាយា** ( ការប្រព្រឹត្តលាក់ពុតបិទបាំងទោស ) ជាឧបក្កិលេសនៃចិត្ត១ **ថម្ភៈ** ( ជាមនុស្ស

❀ ព្រោះលោភៈ ទើបចេះពេញចិត្តចំពោះកិលេសខ្លួនឯង និងកិលេសអ្នកដទៃ ។

❀ ព្រោះតែលោភៈ ទើបអ្វីៗក្នុងលោកមិនមានទីបញ្ចប់ ក៏ព្រោះតែលោភៈពីមួយជាតិទៅមួយជាតិ មិនចេះអស់ក្ស័យ ព្រោះនៅមានលោភៈ ។

❀ សេចក្តីជាប់ជាមួយលោភៈ ជាប់ជំពាក់បំណុលកាម។

យោនិសោមនសិការបទដ្ឋានៅ ការយកចិត្តទុកដាក់ត្រូវតាមហេតុផលឲ្យច្បាស់លាស់ គឺជាហេតុពិតនៃ អលោភៈ។

(ដកស្រង់ចេញពីសៀវភៅជំនួយសតិ ភាគ២)

## ៨. អលោភៈ

❀ អលោភៈ ការមិនជាប់ជំពាក់មាននៅគ្រប់កុសលទាំងអស់ គឺជាមិត្តជួយឱ្យបានសម្រេចនូវអរិយមគ្គ ។

❀ អលោភៈ ធ្វើសីលឱ្យស្អាតទាំងគ្រហស្ថ ទាំងបព្វជិត ។

❋ អលោភៈ ជាបរមត្ថធម៌ ជាសភាវៈពិតប្រព្រឹត្តទៅក្នុងចិត្តល្អ ។

❋ អលគ្គភាវលក្ខណោ មានការមិនជាប់នៅក្នុងអារម្មណ៍ជាលក្ខណៈដូចតំណក់ទឹកមិនជាប់នៅក្នុង គឺសើបត្របកផ្កាឈូក ។

❋ សេចក្តីសន្តោស គឺអលោភៈ អ្នកមានសេចក្តីសន្តោសឈ្មោះថា អ្នកមានធម៌ល្អ សេចក្តីសន្តោសជាទ្រព្យដ៏ប្រសើរក្រៃលែង ។

❋ អលោភៈជាអ្នកមាន ជាអ្នកគ្រប់ ពុំខ្វះខាតឡើយតាមផ្លូវចិត្ត ។

❋ អនល្លីនភាវបច្ចុបដ្ឋានោ មានការមិនប្រកាន់មាំក្នុងអារម្មណ៍ជាផល ដូចបុគ្គលធ្លាក់ក្នុងរណ្តៅស្មោកគ្រោក ហើយមិនត្រូវការនៅក្នុងរណ្តៅនោះ មិនហ៊ួងហែងរណ្តៅនោះឡើយ អារម្មណ៍ក្នុងលោកទាំង ៦ គឺ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ប្រៀបបីដូចជារណ្តៅស្មោក-

❋ គួរសិក្សាពិចារណានូវធម្មៈគ្រប់យ៉ាង ដែលកំពុងប្រាកដក្នុងខណៈនេះ ដែលជាសភាវៈមួយលក្ខណៈៗ សូម្បីអទោសៈក៏ជាធម្មៈ លោភៈក៏ជាធម្មៈ ទោសៈក៏ជាធម្មៈ អលោភៈក៏ជាធម្មៈ មេត្តាក៏ជាធម្មៈ ចិត្តឃើញក៏ជាធម្មៈ ចិត្តឮ ចិត្តធុំ ចិត្តនឹកគិត សុខ ទុក្ខ ។ល។ សភាវៈគ្រប់យ៉ាងសុទ្ធតែជាធម្មៈ ធម្មៈ គឺបរមត្ថធម៌ គឺជាសភាវៈពិត ចិត្ត គឺជាចិត្ត ធាតុ គឺធាតុ រូប គឺរូប មិនទៅជាមនុស្សសត្វបុគ្គលតួខ្លួនយើងគេឡើយ ។

❋ អលោភៈ ជាមូលនៃចិត្ត អលោភៈមាននៅក្នុងចិត្តបុគ្គលណា ចិត្តបុគ្គលនោះរមែងមានសេចក្តីសុខ ព្រោះចេះគ្រប់ ។

❋ អលោភៈ ជាកុសល ។

## ៩.ទោសៈ

● ទុស្សតីតិ ទោសោ ឈ្មោះថាទោសៈ ដោយអត្ថថា ប្រទូសរ៉ាយ ។

● ទោសៈនេះ កើតជាមួយទោសមូលចិត្ត ២ដួង ។

● ទោសៈមិនមែនកើតពីអ្នកដទៃទេ គឺកើតពីកិលេសខ្លួនឯង ។

គប្បីពិចារណា នូវពេលឃើញ អ្នកដទៃមានទោសៈ (គឺខឹងក្រោធ) គួរមានចិត្តមេត្តា ព្រោះថាទោសៈ គឺសេចក្ដីក្រោធ ( អកុសលចិត្ត ) មិនមែនជាប្រយោជន៍ឡើយ ។

*មេត្តា អង្គធម៌ គឺអទោសៈ ។*

មានមេត្តា ព្រោះឃើញដល់បំណងរបស់អ្នកដទៃ ដែលត្រូវការសេចក្ដីសុខដូចយើងដែរ ។

មានមេត្តា មានការលះបង់ ។

មានមេត្តា មានការរាប់អាន ។

មានមេត្តា មានការអើពើ មិនមានការមើលងាយពិតឡើយ ។

មានមេត្តា មានសេចក្ដីសុខជាមួយត្រជាក់របស់ចិត្ត។

មេត្តា ជាគ្រឿងប្រដាប់ចិត្តដ៏ប្រសើរ ។ បានជាត្រូវមានមេត្តា ព្រោះសត្វទាំងឡាយគួរឱ្យមានមេត្តា ។

● អទោសៈ គឺជាកុសលធម៌ ជារបស់ល្អមានសភាពមិនខឹងជាលក្ខណៈ ។ ការមិនខឹងក្រោធ ជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ ។ ការខឹងក្រោធ ជាលក្ខណៈរបស់ទោសៈដែលជាសភាវធម៌សម្រាប់ប្រទូសរ៉ាយដល់ចិត្ត ដោយប្រការផ្សេងៗ ។

គ្រប់គ្នាមិនគួរខឹងក្រោធ ព្រោះនៅពេលខឹងក្រោធហើយវាជាទុក្ខ សេចក្ដីក្រោធរមែងមិនស្អាតដូចសាច់ដែលមានដង្កូវ ។

● ទោសៈ គឺសេចក្ដីក្រោធដូចជាភ្លើង កាលបើកើតក្នុងចិត្តណា ក៏មានការដុតកម្ដោចនូវចិត្តនោះ ដូចជាភ្លើងកើតក្នុងផ្ទះណា ក៏មានការដុតកម្ទេចនូវ ផ្ទះនោះដូច្នោះដែរ ។

គប្បីពិចារណាឱ្យឃើញទោសរបស់សេចក្តីក្រោធ គឺទោសដែលជាអកុសល ។ គួររម្ងាប់សេចក្តីក្រោធ ព្រោះសេចក្តីក្រោធមានទោសបង្កផលអាក្រក់ឱ្យមកសន្ធឹកសន្ធាប់ ដូចជាព្រះពុទ្ធវចនៈបានសម្តែងមកហើយ បញ្ជាក់ឱ្យដឹង ។

១ ក្នុងសៀវភៅ វិធីរម្ងាប់សេចក្តីក្រោធ លោកគ្រូជាម្ចាស់បានសរសេររៀបរៀងថា សេចក្តីក្រោធរមែងសាងនូវសេចក្តីទុក្ខ និងសេចក្តីវិនាសឱ្យដល់បុគ្គលអ្នកមានសេចក្តីក្រោធ ដូច្នេះអ្នកទាំងឡាយ គប្បីពិចារណា ឱ្យឃើញទោសនៃសេចក្តីក្រោធ ក្នុងចំណុចនេះព្រះពុទ្ធបរមគ្រូនៃយើងទ្រង់ត្រាស់សម្តែងទុកមកច្រើនណាស់ ដូចជា :

បុគ្គលក្រោធ រមែងនិយនូវសេចក្តីទុក្ខ បុគ្គលក្រោធរមែងមិនខ្លាចអ្វីឡើយ សេចក្តីខ្មាសក៏មិនមាន សេចក្តីគោរពក៏មិនមាន គេរមែងធ្វើនូវអំពើវិនាសផ្សេងៗ ដូចជាភ្លើងឆេះព្រៃផ្លូវឆ្ពោះឯង ។

សេចក្តីក្រោធ គឺជាទោសៈ ព្រោះគាប់អ្វីស្មើនឹងទោសៈ គឺសេចក្តីក្រោធមិនមាន ។

ក៏បុគ្គលអ្វីស្មើនឹងទោសៈ គឺសេចក្តីក្រោធមិនមាន ។

អក្កោធេន ជិនេ កោធំ ព្រះសាស្តាទ្រង់ទាំងព្រះធម៌ទេសនាឱ្យឈ្នះក្រោធ រស់ដោយមេត្តា ឈ្នះក្រោធឬស្សាដោយការមិនក្រោធ ។

## ១០. អក្កោធៈ

អក្កោធៈ គឺការមិនក្រោធ ( ជាកុសល ) ។

អព្យាបាទលក្ខណា មានការមិនកាចជាលក្ខណៈ ដូចជាមិត្តល្អជួយទំនុកបម្រុង ។

ការមិនក្រោធជួយឱ្យមានបញ្ញាស្មារតី ។

អទោសៈ គឺការមិនខឹងក្រោធ បុគ្គលមិនខឹងក្រោធរមែងរកជាសុខសព្វកាល ។

បុគ្គលអាចមិនក្រោធ ព្រោះមានការអត់ធន់ ( ខន្តី ) ជាជំនួយយ៉ាងសំខាន់ ការអត់ធន់ជាប្រយោជន៍សំខាន់បំផុតក្នុងការយកឈ្នះសេចក្តីក្រោធ គឺទោសៈ ។

បុគ្គលមានទូវសេចក្តីអត់ធន់ រមែងឈ្នះសេចក្តីក្រោធ ។

## ១១. មោហៈ

**អារម្មណេ មុយ្ហតីតិ មោហោ · អញ្ញាណំ**

ឈ្មោះថា មោហៈ ដោយអត្ថថាវង្វេងក្នុងអារម្មណ៍ បានដល់ អញ្ញាណ មោហៈនេះកើតក្នុងអកុសលចិត្ត ១២ ដួង ។

មោហៈ គឺអវិជ្ជា ។

មោហៈធ្វើឱ្យមានការយល់ថា ខ្លួនឯងជាអ្នកបានអ្វីៗអំពីលោកនេះ ហើយត្រេកអរ មានការប្រកាន់ដោយមានះ។

មោហៈ វង្វេងក្នុងលក្ខណៈនៃសភាវៈធម៌ នាំឱ្យប្រកាន់ថាជាតួខ្លួន ឬថាជារបស់ខ្លួន ការមានសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ជាប្រក្រតី ទើបអាចលះបង់នូវមោហៈ អវិជ្ជាឱ្យអស់ទៅបាន ។

ការមិនដឹងថា អវិជ្ជា គឺមិនដឹងបរមត្ថធម៌ក្នុងខណៈឃើញ ឬក្នុងខណៈឮ ឬក្នុងខណៈលោភៈ ទោសៈជាដើម មិនអាចមានការរីកចម្រើនអរិយមគ្គអង្គ ៨ ដើម្បីលះអវិជ្ជាបានឡើយ ។

អមោហៈ គឺបញ្ញាបានដល់ការដឹងច្បាស់តាមសេចក្តីពិតនៃអារម្មណ៍មិនវង្វេងប្រឡំខុសអំពីការពិត ។

## ១២. បញ្ញា

បញ្ញា គឺការឆ្លាតឈ្លាស ជាសម្បត្តិដ៏ប្រសើរ បុគ្គលអ្នកចម្រើនដោយបញ្ញា គឺជាអ្នកបានកម្ចាត់បង់នូវភាពងងឹត គឺមោហៈ ដែលជាអវិជ្ជា ។

បុគ្គលអ្នកមានបញ្ញា គឺជានរជន ជាជនដ៏ប្រសើរ ។ បញ្ញាអាចជួយអ្នកមានគ្រោះឱ្យផុតពីគ្រោះ ។ បញ្ញាអាចជួយអ្នកល្ងង់ឱ្យឆ្លាតឈ្លាស ។

កាលដែលមានសតិរលឹកឃើញ លក្ខណៈពិតនៃសភាវធម៌រឿយៗ ក្នុងជីវិតប្រចាំថ្ងៃ បញ្ញាដឹងច្បាស់ឡើងៗ

នូវអារម្មណ៍ជាបរមត្ថ ក៏ជាការហាមឃាត់នូវកិលេស បិទនូវកិលេស ព្រោះកិលេសកើតតែជាមួយមោហៈ គឺអវិជ្ជា មិនកើតរួមជាមួយសតិបញ្ញាឡើយ ។

បុគ្គលដែលមិនបានអប់រំនូវបញ្ញាទេនោះ មុខតែមិនអាចរួចពីការវង្វេងបានឡើយ គឺវង្វេងព្រោះកាម វង្វេងព្រោះសេចក្ដីក្រោធ វង្វេងព្រោះមោហៈអវិជ្ជា វង្វេងព្រោះមិច្ឆាទិដ្ឋិ ។ ការអប់រំចម្រើនបញ្ញា ប្រព្រឹត្តទៅដើម្បីឃើញច្បាស់នូវលោកក្នុងអរិយវិន័យ វត្ថុអ្វីៗក្នុងលោកសុទ្ធតែសន្មតទាំងអស់ របស់ទាំងអស់នោះមិនផុតចាកអំពីរូបារម្មណ៍ និងធម្មារម្មណ៍ឡើយ អារម្មណ៍ទាំង ៦ នេះ ទើបជាលោកពិត គឺជាលោកដែលមានសភាវៈ មានការកើតព្រាកដជាអារម្មណ៍នៃវិញ្ញាណ ។

បញ្ញាដែលមានកម្លាំងចាស់ក្លា ទើបដឹងច្បាស់ថា ព្រោះអាស្រ័យនូវវត្ថុរូប ប៉ះខ្ទប់គ្នាជាមួយអារម្មណ៍ខាងក្រៅ ទើបវិញ្ញាណកើតឡើងជាវិថីចិត្ត របស់មិនទៀងតែងបាត់ទៅវិញ អស់ទៅវិញជាធម្មតា ។ ការបដិបត្តិ សិក្សាសង្កេត

រលឹកដឹងចំពោះសភាវធម៌ដែលកំពុងព្រាកដ បញ្ញាឃើញច្បាស់នូវលោកសូន្យចាកសត្វ មានតែវិថីចិត្តដឹងអារម្មណ៍ ហើយឃើញការរលត់ទៅនៃលោក ឃើញការរលត់ទៅនៃវិថីចិត្ត ជីវិតពិតជាអនត្តា តែជាទុក្ខ ។

**ទើប** កើតការអប់រំចម្រើនបញ្ញា បញ្ញាដែលចាក់ធ្លុះនូវផលទាំងពួងទុក្ខ រមែងនាំពុទ្ធបរិស័ទឱ្យធ្វើដំណើរទៅតាមស្នាមព្រះបាទនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ រហូតដល់អមតមហានគរ ដែលផុតចាកបញ្ចក្ខន្ធជានគរជរា និងមរណៈ ។

ប៉ុន្តែការកើតបញ្ញាក្ដី ការចម្រើនបញ្ញាក្ដី គឺមិនអាចបង្ខំឱ្យកើត ឬចម្រើនបានដោយការចង់បានឱ្យលឿនៗ ដូចចិត្តបានទេ គឺមិនត្រូវចង់នេះ ចង់ដឹងលឿនជាងកម្លាំងបញ្ញាដែលអាចមានបានឡើយ ។

លោកគ្រូជាម្ចាស់ បានសម្ដែង ក្នុងបទពិចារណា អ្វីៗដែលត្រូវកើត ក៏កើតតាមហេតុបច្ច័យបង្គាប់បញ្ជាមិនបាន ។ លោកនៃជីវិតពិតត្រឹមតែជាអារម្មណ៍នៃវិថីចិត្តប៉ុណ្ណោះ បើ

វីថិចិត្តតាមទ្វារ៦មិនមានទេ លោកធាតុនេះក៏មិនមានដោយពិត នេះគឺជាលោកនៃជីវិតរបស់បុគ្គលម្នាក់ៗ ជីវិតមិនអាចរស់នៅក្នុងលោកបានយូរឡើយ ត្រូវរលត់បាត់ទៅព្រមទាំងលោកក៏បែកធ្លាយដែរ ដូចជាពុំពពុះទឹកដូច្នោះឯង ។

ជីវិត គឺគ្រាន់តែជាផលនៃបច្ច័យប៉ុណ្ណោះ ជីវិតក្នុងលោក ៦ នេះ ពុំដែលមានអ្វីជារបស់ខ្លួនឯងទេ ហើយដែលពិតណាស់ទៅទៀតនោះ ជីវិតពុំមានតួខ្លួនឯងឡើយ ត្រូវវិនាសទៅវិញយ៉ាងឆាប់ដូចជាផ្លេកបន្ទោរដូច្នោះដែរ ។ ការតាក់តែងនូវលោកដោយអំណាចកម្ម គឺអភិសង្ខារ ព្រោះការប្រកាន់ដោយតណ្ហាថា លោកជារបស់ខ្លួនយើង ដូចជាការតាក់តែងរូបឱ្យស្អាត សំឡេងឱ្យពីរោះជាដើម នេះឈ្មោះថាសត្វលោក គឺអ្នកជាប់ជំពាក់នៅក្នុងលោក ។

លោកគ្រូជាម្ចាស់ បានសម្តែងជារឿយៗថា មនុស្សយើងមិនអាចបាននូវអ្វីៗគ្រប់យ៉ាង ទៅតាមការស្រេកឃ្លានដោយអំណាចតណ្ហារបស់ខ្លួនឡើយ ដូច្នេះដើម្បីកុំឱ្យខ្លួនឯងស្លាប់ទៅទាំងការខ្វះខាត រហេមរហាម គឺត្រូវតែប្រញាប់រៀនឱ្យចេះត្រេកអរនឹងរបស់ដែលខ្លួនកំពុងមាននេះឯង ។

គ្រប់គ្នាតបើស្វែងរកសេចក្តីសុខ តាមការណែនាំរបស់ព្រះពុទ្ធ កុំស្វែងរកសុខពីការស្រែកយំនៃអ្នកដទៃឡើយ ។ អ្នកទាំងឡាយ បើចង់បានសុខចូរធ្វើដោយខ្លួនឯង គឺធ្វើខ្លួនឯងឱ្យមានទីពឹង ។

*ព្រះសម្មាសម្ពុទ្ធ ព្រះអង្គត្រាស់សម្តែង*

*ក្នុងបិដកលេខ ១៥ ទំព័រ ១១៥ ។*

គ្រានោះព្រះមានព្រះភាគទ្រង់នៅក្នុងព្រៃជិត មាតុ-លានគរក្នុងដែនមគធៈ ។ ព្រះអង្គទ្រង់ត្រាស់នឹងភិក្ខុទាំង-ឡាយ ចូរមានខ្លួនជាទីពឹង កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។

ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរមានធម៌ជាទីពឹងពំនាក់ កុំមានរបស់ដទៃជាទីពឹងពំនាក់ឡើយ ។ បុគ្គលអ្នកមានធម៌ជាទីពឹងដ៏ប្រសើរ ។ បុគ្គលអ្នកមានធម៌ឃើញធម៌ គឺជាបុគ្គលឃើញព្រះតថាគតដោយពិត ។ ដូច្នេះ

បុគ្គលជាអ្នកចង់បានសេចក្ដីសុខដោយពិត គប្បីចូលមករកព្រះពុទ្ធ ដើម្បីបានជួបព្រះអង្គ គប្បីជាអ្នកបានសិក្សានូវព្រះធម៌ មានការអានសៀវភៅធម៌ ស្ដាប់ធម៌ដោយសេចក្ដីគោរព ។ អានិសង្សនៃការស្ដាប់ព្រះធម៌ដោយសេចក្ដីគោរព ជាការចម្រើននូវបញ្ញាដ៏ក្រៃលែង ។

បញ្ញាកាលបើចាស់ក្លា និងមានកម្លាំងខ្លាំងក្លា គឺប្រៀបដូចព្រះអាទិត្យជះពន្លឺរះបំភ្លឺលោក ព្រះអាទិត្យរះបំភ្លឺលោកយ៉ាងណា បញ្ញាបំភ្លឺខន្ធក៏យ៉ាងនោះដែរ ។

( បញ្ញាក្នុងសេចក្ដីនេះ គឺបញ្ញាចក្ខុ )

បណ្ដាធម៌ជាបាបធម៌ទាំងឡាយ ដែលព្រះសាស្ដាទ្រង់សម្ដែងឱ្យលះបង់ បណ្ដាធម៌ទាំងនោះមាន លោភៈជាបាបធម៌១ ទោសៈជាបាបធម៌១ មជ្ឈិមប្បដិបទា គឺសេចក្ដីប្រតិបត្តិយ៉ាងកណ្ដាល ប្រព្រឹត្តទៅដើម្បីលះបង់នូវលោភៈផង ដើម្បីលះបង់នូវទោសៈផង ជាសេចក្ដីប្រតិបត្តិធ្វើឱ្យកើតបញ្ញាចក្ខុ គឺឃើញនូវសច្ចៈទាំង៤ផង ប្រព្រឹត្តទៅដើម្បីរម្ងាប់កិលេស ដើម្បីដឹងច្បាស់នូវអរិយសច្ចៈ ដើម្បីត្រាស់ដឹងនូវមគ្គ ដើម្បីដល់នូវព្រះនិព្វាន ។

មជ្ឈិមប្បដិបទា គឺជាអរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង ។ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការ គឺ :

| | |
|---|---|
| ១. សម្មាទិដ្ឋិ | ជាបញ្ញាចេតសិក |
| ២. សម្មាសង្កប្បៈ | ជាវិតក្កចេតសិក |
| ៣. សម្មាវាចា | |
| ៤. សម្មាកម្មន្តៈ | ជាវិរតិចេតសិក |
| ៥. សម្មាអាជីវៈ | |
| ៦. សម្មាវាយាមៈ | ជាវិរិយចេតសិក |
| ៧. សម្មាសតិ | ជាសតិចេតសិក |
| ៨. សម្មាសមាធិ | ជាឯកគ្គតាចេតសិក |

. សម្មាទិដ្ឋិ ៖ គឺប្រាជ្ញាជាគ្រឿងដឹងក្នុងកងទុក្ខ ប្រាជ្ញាជាគ្រឿងដឹងក្នុងតណ្ហា ជាដែនឱ្យកើតនៃកងទុក្ខ ប្រាជ្ញាជាគ្រឿងដឹងក្នុងធម៌ ជាទីរលត់នៃកងទុក្ខ ប្រាជ្ញាជាគ្រឿងដឹងក្នុងដំណើរជាទីទៅកាន់ទីរលត់ទុក្ខ ។

- **សម្មាសង្កប្បៈ** ៖ គឺសេចក្តីត្រិះរិះក្នុងកិរិយាចេញចាកកាម១ សេចក្តីត្រិះរិះក្នុងកិរិយាមិនព្យាបាទ១ សេចក្តីត្រិះរិះក្នុងកិរិយាមិនបៀតបៀន១ ។

- **សម្មាវាចា** ៖ គឺចេតនាវៀរចាកមុសាវាទ១ ចេតនាវៀរចាកបិសុណាវាចា១ ចេតនាវៀរចាកផរុសវាចា១ ចេតនាវៀរចាកសម្ផប្បលាបៈ១ ។

- **សម្មាកម្មន្តៈ** ៖ ចេតនាវៀរចាកបាណាតិបាត១ ចេតនាវៀរចាកអទិន្នាទាន១ ចេតនាវៀរចាកភាមេសុមិច្ឆាចារ១ ។

- **សម្មាអាជីវៈ** ៖ អរិយសាវ័កក្នុងសាសនានេះ លះបង់នូវមិច្ឆាជីវៈ គឺការចិញ្ចឹមជីវិតខុស ហើយប្រព្រឹត្តតែការចិញ្ចឹមជីវិតត្រូវ ។

- **សម្មាវាយាមៈ** ៖ ការញុំាងឆន្ទៈឱ្យកើត ធ្វើនូវព្យាយាម ប្រារព្ធព្យាយាមផ្គងចិត្ត តាំងចិត្ត ដើម្បីធ្វើអកុសលធម៌ទាំងឡាយដ៏ណាមក ដែលមិនទាន់កើតឡើង មិនឱ្យកើតឡើងបាន ធ្វើឆន្ទៈឱ្យកើត ធ្វើព្យាយាម ប្រារព្ធព្យាយាម ផ្គងចិត្ត តាំងចិត្តដើម្បីលះបង់ នូវអកុសលធម៌ទាំងឡាយដ៏លាមកដែលកើតឡើងហើយឱ្យសាបសូន្យទៅ។ល។

- **សម្មាសតិ** ៖ គឺការពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតីគ្រប់ឥរិយាបថទាំង៤ មានព្យាយាមជាគ្រឿងដុតកម្តៅនូវកិលេស មានសេចក្តីដឹងខ្លួន និងមានសតិបន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។ ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនា ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ ។

- **សម្មាសមាធិ** ៖ គឺសេចក្តីស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិ និងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ជាអារម្មណ៍ ។

*ក្នុងសៀវភៅមេរៀនធម៌ (ជំនួយសិក្សាទី ៤)*

លោកគ្រូជាម្ចាស់បានសរសេរថា ៖ សតិបដ្ឋាន ដែលនៅជាលោកិយ មានមគ្គអង្គ៥ គឺ *សម្មាទិដ្ឋិ១ សម្មា-*

សង្កប្បៈ១ សម្មាវាយាមៈ១ សម្មាសតិ១ សម្មាសមាធិ១ មគ្គអង្គ ៥ នេះ កាលដែលចម្រើនឱ្យច្រើនហើយ ក៏រមែងបានគ្រប់នូវអង្គ ៨ប្រការ ជាលោកុត្តរ ព្រោះថាការចម្រើនសតិប្បដ្ឋាន ៤ គឺមហាកុសលញាណសម្បយុត្ត មានតទង្គ-ប្បហានជាកិច្ច មានព្រះនិព្វានជាទីបង្អោនទៅ នេះដោយ-សារមហាកុសលញាណសម្បយុត្ត គឺជាវិបស្សនាញាណ មានបរមត្ថធម៌ជាអារម្មណ៍ ។

វិបស្សនាញាណ មិនមែនមានពូជនៅក្នុងសមាបត្តិ ៨ទេ ទោះជាសមាបត្តិណាមួយក៏ដោយ ពីព្រោះសមាបត្តិ ៨ មិនមានអារម្មណ៍នាំឱ្យកើតវិបស្សនាទេ មានតែសតិប្បដ្ឋានប៉ុណ្ណោះ ដែលមានអារម្មណ៍នាំមកនូវវិបស្សនា ពុទ្ធបរិស័ទគួរសិក្សាសតិប្បដ្ឋានសូត្រឱ្យបានច្បាស់លាស់ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្ដែងនូវព្រះសទ្ធម្ម បញ្ញាថ្នាក់ស្ដាប់ព្រះធម៌យល់ចូលចិត្ត អាចគាត់តែងឱ្យមានសតិរលឹកសតិប្បដ្ឋាន ៤ នាំឱ្យបាននូវអរិយមគ្គប្រកបដោយអង្គ ៨ប្រការ ។

● មហាសតិប្បដ្ឋានសូត្រ ក្នុងបិដកលេខ ១៧ សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ ដកស្រង់សរសេរដោយសង្ខេប ។

( ១១១ ) ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកម្មាសទម្មនិគមរបស់អ្នកកុរុក្នុងដែនកុរុ ។ ព្រះអង្គទ្រង់ត្រាស់ នឹងភិក្ខុទាំងឡាយយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ផ្លូវ គឺសតិប្បដ្ឋានទាំង ៤ ( ជាផ្លូវមួយតែមួយ ) ប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីលះបង់នូវសេចក្ដីសោក និងសេចក្ដីខ្សឹក-ខ្សួល ដើម្បីរំលត់នូវទុក្ខ និងទោមនស្ស ដើម្បីបាន នូវអរិយ-មគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

សតិប្បដ្ឋាន ៤ តើជាអ្វីខ្លះ ព្រះមានព្រះភាគទ្រង់ត្រាស់ព្រះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿង ដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( គ្រឿងកំណត់ ) កម្ចាត់បង់នូវ

អភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។

ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំង-ឡាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួនមានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។

ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។

ពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ មានព្យាយាមជាគ្រឿង-ដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី ( ជាគ្រឿងកំណត់ ) កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញ ។

## ១៣. សតិប្បដ្ឋានសូត្រទី១០

*សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ*
*បឋមភាគ ២០ មូលបរិយាយវគ្គ សតិប្បដ្ឋានសូត្រ*
*ធាតុបព្វៈ និងនវសីវថិកាបព្វៈ*

ព្រះមានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ម្នាល-ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយឬក៏ឃើញនូវកាយនេះឯង ដែលស្ថិតនៅហើយយ៉ាងណា ដែលតម្កល់នៅហើយយ៉ាងណា ដោយកំណត់ថាជាធាតុប្លេះថា ក្នុងកាយនេះជាបឋវីធាតុ អាបោធាតុ តេជោធាតុ និងវាយោធាតុ ។ ភិក្ខុទាំងឡាយ ពិចារណាឃើញរឿយៗ នូវកាយជាខាងក្នុង ( ដោយការកំណត់នូវអសុភ ដែលសត្វស៊ីជាដើម ) ពិចារណាឃើញរឿយៗ នូវសមុទយធម៌ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង៤ក្តី ពិចារណាឃើញរឿយៗ នូវសមុទយធម៌ និងវយធម៌ក្នុងកាយជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ក្តី

ពុំនោះសោតស្មារតីរបស់ភិក្ខុនោះក៏ផ្ចង់ឡើង ចំពោះថា កាយនេះមានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) ។

*ចប់កាយានុបស្សនាសតិប្បដ្ឋាន ។*

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ (ដោយការកំណត់នូវវេទនា មានសុខវេទនាជាដើម) ពិចារណាឃើញរឿយៗ នូវធម៌ដែលប្រជុំកើតឡើង ទាំងធម៌ដែលសូន្យទៅក្នុងវេទនាទាំងឡាយ គ្រប់ឥរិយាបថទាំង ៤ ពុំនោះសោតស្មារតី (ជាគ្រឿងកំណត់នូវវេទនា) ក៏ផ្ចង់ឡើងថា វេទនាមានមែន (តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម) គ្រាន់តែជាទីកំណត់ដើម្បីឲ្យចម្រើនប្រាជ្ញា ដើម្បីឲ្យចម្រើនស្មារតីប៉ុណ្ណោះ ។ មានចិត្តមិនអាស្រ័យ (ដោយតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ) ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ផង មិនប្រកៀកប្រកាន់អ្វី

តិចតួចក្នុងលោកផង ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

*ចប់វេទនានុបស្សនាសតិប្បដ្ឋាន ។*

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ពិចារណាឃើញរឿយៗ កំណត់ដឹងនូវចិត្ត ទោះចិត្តនោះប្រកបដោយ រាគៈ (គឺលោភមូល៨ប្រការ) ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ទោះចិត្តប្រាសចាករាគៈ (គឺលោកិយកុសលចិត្ត និងអព្យាកតចិត្ត) ក៏ដឹងច្បាស់ថាចិត្តប្រាសចាករាគៈ ។ ទោះចិត្តប្រកបដោយទោសៈ (គឺទោសមូល ២ ប្រការ) ក៏ដឹងច្បាស់ចិត្តប្រកបដោយទោសៈ ទោះចិត្តប្រាសចាកទោសៈ (គឺលោកិយ-កុសលចិត្ត និងអព្យាកតចិត្ត) ក៏ដឹងច្បាស់ថាចិត្តប្រាសចាកទោសៈ ។ ទោះចិត្តប្រកបដោយមោហៈ (គឺមោហមូល ២ ប្រការ) ក៏ដឹងច្បាស់ថាចិត្តប្រកបដោយមោហៈ ទោះចិត្តប្រាសចាកមោហៈ (គឺលោកិយកុសលចិត្ត និងអព្យាកតចិត្ត)

ក៏ដឹងច្បាស់ថាចិត្តប្រកបដោយមោហៈ ។ ទោះចិត្តរួញរា ( គឺចិត្តដែលចិនមិទ្ធៈគ្របសង្កត់ ) ក៏ដឹងច្បាស់ថាចិត្តរួញរា ។ ទោះចិត្តរាយមាយ ( គឺឧទ្ធច្ចសហគតចិត្ត ) ក៏ដឹងច្បាស់ថាចិត្តរាយមាយ ។ ទោះចិត្តដល់នូវភាវៈប្រសើរ ( គឺជារូបាវចរចិត្ត និងអរូបាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តដល់នូវភាវៈប្រសើរ ទោះចិត្តមិនដល់នូវភាវៈប្រសើរ ( គឺកាមាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តមិនដល់នូវភាវៈប្រសើរ ។ ទោះចិត្តនៅមានចិត្តដទៃប្រសើរជាង ( គឺកាមាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តនៅមានចិត្តដទៃប្រសើរជាង ទោះចិត្តមិនមានចិត្តដទៃប្រសើរជាង ( គឺរូបាវចរចិត្ត និងអរូបាវចរចិត្ត ) ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃប្រសើរជាង ។ ទោះចិត្តតម្កល់នៅមាំ ( គឺជាអប្បនាសមាធិ និងឧបចារសមាធិ ) ក៏ដឹងច្បាស់ថា ចិត្តតម្កល់នៅមាំ ទោះចិត្តមិនតម្កល់នៅមាំ ( គឺប្រាសចាកសមាធិទាំង ២ ) ក៏ដឹងច្បាស់ថាចិត្តមិនតម្កល់នៅមាំ ។ ទោះចិត្តរួចស្រឡះ ក៏ដឹងច្បាស់ថាចិត្តរួចស្រឡះ ទោះចិត្តមិនរួចស្រឡះ ក៏ដឹងច្បាស់ថាចិត្តមិនរួចស្រឡះ ។

ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្តជាខាងក្នុង និងខាងក្រៅជាប្រក្រតី គ្រប់ឥរិយាបថទាំង ៤ ពិចារណាឃើញរឿយៗ នូវធម៌ដែលសូន្យទៅក្នុងចិត្តជាប្រក្រតី ពិចារណាឃើញរឿយៗ នូវធម៌ជាទីប្រជុំកើតឡើងមានស្មារតីកំណត់ដឹងថា ចិត្តមានមែន ( តែមិនមែនសត្វ មិនមែនបុគ្គល មិនមែនស្រី មិនមែនប្រុសជាដើម ) គ្រាន់តែជាទីកំណត់ ដើម្បីចម្រើនព្រាជ្ញាស្មារតីប៉ុណ្ណោះ ដើម្បីមានចិត្តមិនអាស្រ័យ ( តណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ ) គ្រប់ឥរិយាបថទាំង៤ ផង មិនប្រកៀកប្រកាន់អ្វីតិចតួចក្នុងលោកផង ។

*ចប់ចិត្តានុបស្សនាសតិប្បដ្ឋាន ។*

ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី គឺនីវរណៈទាំង៥យ៉ាង គ្រប់ឥរិយាបថទាំង ៤ ។ នីវរណៈ៥យ៉ាងនោះ គឺ **កាមច្ឆន្ទៈ១ ព្យាបាទ១ ថីនមិទ្ធៈ១ ឧទ្ធច្ចកុក្កុច្ចៈ១ វិចិកិច្ឆា១** ។

*( នីវរណបព្វៈ ) ។*

ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ គឺឧបាទានក្ខន្ធទាំង ៥ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ។ ឧបាទានក្ខន្ធ ៥ នោះ គឺ រូប១ វេទនា១ សញ្ញា១ សង្ខារ១ វិញ្ញាណ១ ។ ( *ខន្ធបព្វៈ* ) ។

ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺ អាយតនៈ ៦ ទាំងខាងក្រៅ និងខាងក្នុង ( មានខាងក្រៅ ៦ និងខាងក្នុង ៦ រួមជា ១២ ) ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ។

*អាយតនៈ ៦ នោះ គឺ ( ខាងក្នុង និងខាងក្រៅ )*

| **អាយតនៈខាងក្នុង ៦** | **អាយតនៈខាងក្រៅ ៦** |
|---|---|
| .ចក្ខាយតនៈ ១ | .រូបាយតនៈ ១ |
| .សោតាយតនៈ ១ | .សទ្ទាយតនៈ ១ |
| .ឃានាយតនៈ ១ | .គន្ធាយតនៈ ១ |
| .ជិវ្ហាយតនៈ ១ | .រសាយតនៈ ១ |
| .កាយាយតនៈ ១ | .ផោដ្ឋព្វាយតនៈ ១ |
| .មនាយតនៈ ១ | .ធម្មាយតនៈ ១ |

ភិក្ខុទាំងឡាយ ពិចារណាឃើញរឿយៗ នូវសមុទយធម៌ និងវយធម៌គ្រប់ឥរិយាបថទាំង៤ ។ ( *អាយតនបព្វៈ* ) ។

ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ទាំងឡាយ គឺពោជ្ឈង្គ ( អង្គធម៌ជាគ្រឿងត្រាស់ដឹង ) ៧ ប្រការ ជាប្រក្រតីគ្រប់ឥរិយាបថទាំង ៤ ។ ពោជ្ឈង្គ ៧ប្រការ គឺ

. សតិសម្ពោជ្ឈង្គ១

. ធម្មវិចយសម្ពោជ្ឈង្គ១

. វីរិយសម្ពោជ្ឈង្គ១

. បីតិសម្ពោជ្ឈង្គ១

. បស្សទ្ធិសម្ពោជ្ឈង្គ១

. សមាធិសម្ពោជ្ឈង្គ១

. ឧបេក្ខាសម្ពោជ្ឈង្គ១ ។ ( *ពោជ្ឈង្គបព្វៈ* ) ។

ម្នាលភិក្ខុទាំងឡាយ មួយទៀតភិក្ខុពិចារណាឃើញរឿយៗ នូវធម៌ក្នុងធម៌ គឺអរិយសច្ចទាំង ៤ គ្រប់ឥរិយាបថទាំង ៤ ។ អរិយសច្ច ៤ គឺ ទុក្ខ ទុក្ខសមុទយ ទុក្ខនិរោធ

ទុក្ខនិរោធគាមិនីបដិបទា ។

## ១៤. សតិបដ្ឋានសូត្រ ទុក្ខអរិយសច្ចៈ

### បិដកលេខ ២០ ទំព័រ ២២០

ទុក្ខអរិយសច្ច ជាតិក៏ជាទុក្ខ ជរាក៏ជាទុក្ខ មរណៈក៏ជាទុក្ខ សោកៈ បរិទេវៈ គឺសេចក្ដីសោកខ្សឹកខ្សួល ទុក្ខៈ គឺសេចក្ដីលំបាកកាយ ទោមនស្សៈ គឺសេចក្ដីអាក់អន់ក្នុងចិត្ត ឧបាយាសៈ គឺសេចក្ដីចង្អៀតចង្អល់ចិត្ត ក៏សុទ្ធតែជាទុក្ខ អប្បិយេហិសម្បយោគៈ គឺដំណើរជួបប្រសព្វដោយសត្វ និងសង្ខារទាំងឡាយ ដែលមិនជាទីស្រឡាញ់ ក៏ជាទុក្ខ បិយេហិវិប្បយោគៈ គឺសេចក្ដីព្រាត់ប្រាសចាកសត្វនិងសង្ខារទាំងឡាយដែលជាទីស្រឡាញ់ ក៏ជាទុក្ខ យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ គឺបុគ្គលចង់បាននូវរបស់ណាហើយ មិនបាននូវរបស់នោះក៏ជាទុក្ខ បើពោលដោយសេចក្ដីបង្រួញឧបាទានក្ខន្ធ ៥ មានរូបក្ខន្ធជាដើម ក៏ជាទុក្ខ ។

៙ ទុក្ខសមុទយអរិយសច្ច ។ តណ្ហាណា ជាធម្មជាតិនាំសត្វឱ្យកើតទៀត ប្រកបដោយតម្រេករីករាយ ជាធម្មជាតិនាំសត្វឱ្យត្រេកត្រអាលនៅក្នុងភពនោះៗ ឬអារម្មណ៍នោះៗ តណ្ហានោះ គឺកាមតណ្ហា (សេចក្ដីប្រាថ្នាក្នុងកាម) ១ ភវតណ្ហា (សេចក្ដីប្រាថ្នាក្នុងរូបភព និងអរូបភព) ១ វិភវតណ្ហា (សេចក្ដីប្រាថ្នាក្នុងភពសូន្យ) ១ ។ តណ្ហាកាលកើតក្នុងអារម្មណ៍ណា ក៏ជាប់ក្នុងអារម្មណ៍នុ៎ះ អារម្មណ៍អ្វីមួយដែលមានសភាវៈគួរស្រឡាញ់ មានសភាវៈគួរត្រេកអរក្នុងលោកមានភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្ត មានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ។

*ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនោវិញ្ញាណ* មានសភាវៈគួរស្រឡាញ់ គួរត្រេកអរក្នុងលោក ។

*ចក្ខុសម្ផស្ស សោតសម្ផស្ស ឃានសម្ផស្ស ជិវ្ហាសម្ផស្ស កាយសម្ផស្ស មនោសម្ផស្ស* មានសភាវៈគួរស្រឡាញ់ គួរត្រេកអរក្នុងលោក តណ្ហានុ៎ះកាលកើតឡើង

ក៏កើតតែក្នុងសម្ផស្សដែលកើតអំពីសភាវៈនោះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសភាវៈនោះ ។

ចក្ខុសម្ផស្សជាវេទនា សោតសម្ផស្សជាវេទនា ឃានសម្ផស្សជាវេទនា ជិវ្ហាសម្ផស្សជាវេទនា កាយសម្ផស្សជាវេទនា មនោសម្ផស្សជាវេទនា មានសភាវៈគួរស្រឡាញ់ គួរត្រេកអរក្នុងលោក តណ្ហានុ៎ះកាលកើតឡើង ក៏កើតតែក្នុងវេទនា ដែលកើតអំពីសភាវៈនោះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងសភាវៈនោះ ។

*រូបសញ្ញា* ( គឺសេចក្ដីសម្គាល់ក្នុងរូប ) សទ្ទសញ្ញា ( គឺសេចក្ដីសម្គាល់ក្នុងសំឡេង ) *គន្ធសញ្ញា* ( គឺសេចក្ដីសម្គាល់ក្នុងក្លិន ) *រសសញ្ញា* ( គឺសេចក្ដីសម្គាល់ក្នុងរស ) *ផោដ្ឋព្វសញ្ញា* ( គឺសេចក្ដីសម្គាល់ក្នុងផោដ្ឋព្វៈ ) *ធម្មសញ្ញា* ( គឺសេចក្ដីសម្គាល់ក្នុងធម្មារម្មណ៍ ) ។

*រូបសញ្ចេតនា* (សេចក្ដីគិតការគិតសន្សំនូវរូបារម្មណ៍) *សទ្ទសញ្ចេតនា គន្ធសញ្ចេតនា រសសញ្ចេតនា ផោដ្ឋព្វសញ្ចេតនា ធម្មសញ្ចេតនា* ។

*រូបតណ្ហា* ( សេចក្ដីស្រេកឃ្លានក្នុងរូបារម្មណ៍) *សទ្ទតណ្ហា គន្ធតណ្ហា រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា* ។

*រូបវិតក្កៈ* ( សេចក្ដីត្រិះរិះក្នុងរូបារម្មណ៍) *សទ្ទវិតក្កៈ គន្ធវិតក្កៈ រសវិតក្កៈ ផោដ្ឋព្វវិតក្កៈ ធម្មវិតក្កៈ* ។

*រូបវិចារៈ* ( សភាពពិចារណានូវរូបារម្មណ៍ ) *សទ្ទវិចារៈ គន្ធវិចារៈ រសវិចារៈ ផោដ្ឋព្វវិចារៈ ធម្មវិចារៈ* មានសភាវៈគួរស្រឡាញ់ គួរត្រេកអរក្នុងលោក តណ្ហានុ៎ះកាលកើតឡើង ក៏កើតឡើងក្នុងសេចក្ដីពិចារណានូវរូបជាដើមនុ៎ះ កាលដែលជាប់នៅ ក៏ជាប់នៅក្នុងរូបជាដើមនុ៎ះ ។ ម្នាលភិក្ខុទាំងឡាយ នេះតថាគតហៅថា *ទុក្ខសមុទយអរិយសច្ច* ។

❀ ទុក្ខនិរោធអរិយសច្ច ។ កិរិយាប្រាសចាកតម្រេក រលត់មិនមានសេសសល់ដោយអរិយមគ្គ កិរិយាលះបង់ កិរិយារលាស់ចេញ ការរួចស្រឡះ ការមិនអាល័យនូវតណ្ហានោះឈ្មោះថា *ទុក្ខនិរោធអរិយសច្ច* ។

❀ ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ គឺអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ( បានសរសេរពីខាងដើម ) មាន

សម្មាទិដ្ឋិ ( ប្រាជ្ញាយល់ត្រូវ ) ១ សម្មាសង្កប្បៈ ( ប្រាជ្ញាត្រិះរិះត្រូវ )១ សម្មាវាចា ( ការនិយាយពាក្យត្រូវ )១ សម្មាកម្មន្តៈ ( ការងារត្រូវ ) ១ សម្មាអាជីវៈ ( ការចិញ្ចឹមជីវិតត្រូវ ) ១ សម្មាវាយាមៈ ( សេចក្ដីព្យាយាមត្រូវ )១ សម្មាសតិ (ការតម្កល់ស្មារតីត្រូវ ) ១ សម្មាសមាធិ ( ការតាំងចិត្តតម្កល់នឹងត្រូវ ) ១ ។

៙ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់សម្ដែង ម្នាលភិក្ខុទាំងឡាយ ផ្លូវ គឺសតិប្បដ្ឋាន ៤ នេះឯង ជាផ្លូវមូលតែមួយ ប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធ ដោយវិសេសនៃសត្វទាំងឡាយ ដើម្បីកន្លងបង់នូវសេចក្ដីសោកខ្សឹកខ្សួល ដើម្បីរំលត់នូវទុក្ខ និងទោមនស្ស ដើម្បីបាននូវអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវព្រះនិព្វាន ។

៙មហាបរិនិព្វានសូត្រ ពុទ្ធភាណវារៈ ព្រះឧទានរបស់ព្រះមានព្រះភាគ។ បិដកលេខ១៦ ទំព័រ១៩៣-១៩៤ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់គង់នៅកោដិគ្រាម ក្នុងទីនោះឯង ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតក្ដី អ្នកទាំងឡាយក្ដី ដែលអន្ទោលទៅត្រាច់រង្គាត់ទៅក្នុងសង្សារវដ្ដ អស់កាលយូរអង្វែងយ៉ាងនេះ ក៏ព្រោះមិនបានត្រាស់ដឹង មិនបានចាក់ធ្លុះនូវអរិយសច្ចទាំង ៤ នេះឯង ។

( ៨៧ ) ការត្រាច់រង្គាត់ទៅអស់កាលជាអង្វែង ក្នុងជាតិនោះៗ ក៏ព្រោះតែមិនបានឃើញនូវអរិយសច្ចទាំង ៤ តាមសេចក្ដីពិត ។ ឯអរិយសច្ចទាំង ៤ នោះ បើបុគ្គលបានឃើញហើយ ខ្សែ គឺតណ្ហា ដែលអាចនាំសត្វពីភពមួយទៅភពមួយក៏ដាច់ឫសគល់របស់ទុក្ខ ភពថ្មីទៀតក្នុងកាលឥឡូវនេះមិនមានឡើយ ។

.លោកគ្រូជាម្ចាស់ បានសម្ដែង ខ្ញុំបានស្ដាប់មកថា ព្រះពុទ្ធគ្រប់ៗព្រះអង្គតែងទូន្មានថា អ្នកទាំងឡាយ ចូរប្រព្រឹត្តនូវសុចរិត ៣យ៉ាង គឺកាយសុចរិត (ជាការធ្វើល្អ )១ វចីសុចរិត ( ជាការនិយាយល្អ )១ មនោសុចរិត ( ជាការគិតល្អ)១ ព្រោះសុចរិត ៣យ៉ាងនេះ ជាអាហារនៃសតិប្បដ្ឋាន ៤

ងការអប់រំចម្រើននូវសតិប្បដ្ឋាន ៤ ជាការចម្រើនវិបស្សនាភាវនា ។ ដោយក្នុងព្រះពុទ្ធសាសនា មានការចង្អុលបង្ហាញពីការបដិបត្តិ ដើម្បីរួចផុតចាកទុក្ខ ពុទ្ធបរិស័ទបានអប់រំចម្រើនវិបស្សនាអាស្រ័យសតិប្បដ្ឋាន ៤ ក៏បានត្រាស់ដឹងនូវអរិយសច្ចធម៌ បានឃើញនូវជីវិតសត្វ និងគ្រប់សង្ខារធម៌ទាំងអស់ជារបស់សោះសូន្យទទេ គឺគ្រាន់តែជាផលរបស់ហេតុបច្ច័យតែប៉ុណ្ណោះ រំលត់នូវសេចក្តីប្រកាន់ថាមានតួខ្លួន និងថាមានតួខ្លួនជាអ្នកធ្វើនូវកុសលផ្សេងៗជាដើម ។

សេចក្តីនេះដោយអាស្រ័យសតិប្បដ្ឋាន រលឹកសិក្សាចំពោះសភាវធម៌ជាទូទៅ មិនចំពោះថាជាកុសលធម៌ ឬជាអកុសលធម៌ ឬជាអព្យាកតធម៌ឡើយ ហើយទោះជាតាំងនៅក្នុងភេទអ្វីក៏ដោយ ។ សភាវធម៌ទាំងឡាយត្រូវបានរៀបចំដោយហេតុបច្ច័យទាំងអស់ ។

.បុគ្គលអ្នកចម្រើនសតិប្បដ្ឋាន មិនបានឃើញសតិ-វិបស្សនា មានការចម្រើនឡើង កើតឡើងដោយតួខ្លួន ជាអ្នកធ្វើឱ្យចម្រើន ឱ្យកើតនោះឡើយ គឺបានដឹង បានឃើញ

តាមពិតនូវការចម្រើនឡើង កើតឡើងនៃសតិវិបស្សនានោះ ព្រោះហេតុពិតៗសូន្យចាកតួខ្លួន ជាអ្នកបង្គាប់បញ្ជា សតិសូន្យចាកតួខ្លួនក្នុងលោក ភ្នែកសូន្យចាកតួខ្លួនក្នុងលោក ត្រចៀកសូន្យចាកតួខ្លួនក្នុងលោក ច្រមុះសូន្យចាកតួខ្លួនក្នុងលោក អណ្តាតសូន្យចាកតួខ្លួនក្នុងលោក កាយសូន្យចាកតួខ្លួនក្នុងលោកចិត្ត សូន្យចាកតួខ្លួនក្នុងលោក តាមពិតធម៌ទាំងឡាយកើតអំពីហេតុ ។ វិបស្សនាក៏ព្រោះអាស្រ័យហេតុបច្ច័យផ្សេងៗ ដែលពុំមានបរមត្ថជាសត្វបុគ្គលដើម្បីធ្វើធម៌ បង្កើតធម៌ឡើយ ។

.បុគ្គលអ្នកចម្រើនដោយ សតិវិបស្សនា ជាបុគ្គលមានទីពឹងដ៏ប្រសើរ ព្រោះសតិវិបស្សនា ជាគ្រឿងហាមរាំងនូវត្រសែរបស់តណ្ហា តណ្ហាក្នុងលោក ៦ ( គឺលោក-ភ្នែក លោកត្រចៀក លោកច្រមុះ លោកអណ្តាត លោក-កាយ លោកចិត្ត ) ប្រៀបដូចខ្លាមានមាត់ ៦ ស៊ីអាហារ ៦ ប្រភេទ ខ្លាតណ្ហានេះស៊ីចំណី ចំណីអាហារ គឺអារម្មណ៍ ៦ ស៊ីមិនចេះឆ្អែត កាន់តែស៊ីកាន់តែឃ្លាន សេចក្តីសោកខ្សឹក-

ខ្សឹល សេចក្តីភ័យខ្លាច ព្រោះតណ្ហាជាបច្ច័យ បើតណ្ហាមិនមានទេ សេចក្តីសោកខ្សឹកខ្សួល សេចក្តីភ័យខ្លាចក៏មិនមានដែរ ។

ភ្លើងមិនឆ្អែតដោយអុស សមុទ្រមិនឆ្អែតដោយទឹក តណ្ហាមិនឆ្អែតនឹងអារម្មណ៍ដែលជាទីប្រាថ្នាត្រូវការឡើយ ។

❀ ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់សម្តែង នូវពួកធម៌ដែលជាអារម្មណ៍របស់អកុសល ឱ្យជាទីតាំងនៃវិបស្សនា ក្នុងការបណ្តេញចេញ ឬលះបង់ចោលនូវអកុសលធម៌ មានសេចក្តីប្រកាន់ជាដើម ។

ព្រះអង្គសម្តែងលោកិយធម៌ ទោះជាកុសលក្តី ជាអកុសលក្តី ជាអព្យាកតក្តី ជាអារម្មណប្បច្ច័យនៃវិបស្សនា ព្រោះកិច្ចការនេះប្រព្រឹត្តទៅក្នុងការហាមឃាត់ រារាំងនូវអកុសលធម៌ ដោយមកអំពីអកុសលធម៌ មានតែលោកិយធម៌ជាអារម្មណ៍ប៉ុណ្ណោះ ។ ព្រះអង្គសម្តែងអំពីការកើតឡើងនៃសភាវធម៌ក្នុងជីវិតរាល់ថ្ងៃ បើសភាវធម៌ពិតទាំងអស់បានត្រាស់ជាបរមត្ថសុទ្ធៗដល់បញ្ញាហើយនោះ ការចង់បានអ្វីៗយកមកឱ្យខ្លួនក៏ត្រូវធូរថយ ជាពិសេស ការចង់បានធម៌នេះធម៌នោះផ្សេងៗ ក៏ត្រូវលែងមានតទៅទៀតហើយ ព្រោះបានដឹងច្បាស់ថា ការបានឃើញធម៌ពិត ក្នុងជីវិតប្រចាំថ្ងៃច្បាស់ឡើងៗដោយសតិប្បដ្ឋានបដិបត្តិ ពិតជារំលត់សេចក្តីប្រកាន់បាន កុំមានសង្ស័យ ។

*(ដកស្រង់ពីសៀវភៅជំនួយសតិភាគទី ៤) ។*

❀ ក្នុងវស្សាទី៤៥ ជាវស្សាចុងក្រោយ ។ ក្រោយពេលព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ដាក់ព្រះជន្មាយុសង្ខារ ព្រះអង្គ ទ្រង់ត្រាស់ដាស់តឿនភិក្ខុមិនឱ្យប្រមាទ ហើយទ្រង់សម្តែងព្រះគាថា :

ពពួកជនទាំងក្មេងទាំងចាស់ ទាំងពាលទាំងបណ្ឌិត ទាំងអ្នកមានទាំងអ្នកក្រ សុទ្ធតែមានសេចក្តីស្លាប់នៅខាងមុខ ភាជនៈដីដែលជាងឆ្នាំងសូនឡើងហើយ ទោះតូចក្តី ធំក្តី ឆៅក្តី ឆ្អិនក្តី នឹងមានការបែកជាទីបំផុត ដូចម្តេចមិញ ជីវិតរបស់សត្វទាំងឡាយក៏ដូច្នោះដែរ ។

ម្នាលអ្នកទាំងឡាយ វ័យរបស់តថាគតចាស់ហើយ ជីវិតរបស់តថាគតសល់តិច តថាគតនឹងលះពួកអ្នកទៅ តថាគតបានធ្វើទីពឹងដល់ខ្លួនហើយ ពួកអ្នកចូរកុំប្រមាទ មានសតិ មានសីលដោយល្អចុះ ចូរជាអ្នកមានសេចក្ដីត្រិះរិះតាំងមាំដោយល្អ ចូរតាមរក្សាចិត្តរបស់ខ្លួនចុះ ។

## ១៥.ជំនួយសតិភាគទី ១១ ទំព័រ ១២៧

## ២៣.ធម្មបទគាថា យមកវគ្គទី ១

## បិដកលេខ ៥២ ទំព័រ ២១

### ១.ប្រារព្ធព្រះចក្ខុបាលត្ថេរធ្លាប់ធ្វើបាបពីមុនមក

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បទុដ្ឋេន ភាសតិ វា ករោតិ វា
តតោ នំ ទុក្ខមន្វេតិ ចក្កំវ វហតោ បទំ ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត ( មានចិត្តជាធំ ) សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តត្រូវទោស [១] ប្រទូស្តហើយពោលក្ដី ធ្វើក្ដី ( រមែងជាទុច្ចរិត ) ព្រោះទុច្ចរិតទាំងនោះ ទុក្ខរមែងជាប់តាមបុគ្គលនោះទៅ ដូចកង់រទេះវិលតាមដានជើងគោដែលកំពុងអូសទៅ ។

### ២. ប្រារព្ធមដ្ឋកុណ្ឌលីជ្រះថ្លានឹងព្រះសម្មាសម្ពុទ្ធ

មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា
មនសា ចេ បសន្នេន ភាសតិ វា ករោតិ វា
តតោ នំ សុខមន្វេតិ ឆាយាវ អនុបាយិនី ។

ធម៌ទាំងឡាយ មានចិត្តជាប្រធាន មានចិត្តប្រសើរបំផុត សម្រេចអំពីចិត្ត បើបុគ្គលមានចិត្តជ្រះថ្លា [២] ហើយពោលក្ដី ធ្វើក្ដី ( រមែងជាសុចរិត ) ព្រោះសុចរិតទាំងនោះ សុខរមែងជាប់តាមបុគ្គលនោះទៅ ដូចស្រមោលអន្ទោលតាមប្រាណ ។

---

[១] ធម៌ជាទោស ឬជាអកុសលដែលកើតអំពីចិត្តមានអភិជ្ឈាជាដើម ដែលបុគ្គលមកធ្វើចិត្តឲ្យកើត ។
[២] ជ្រះថ្លាដោយគុណមានអនភិជ្ឈាជាដើម ។ អដ្ឋកថា ។

១៦_ជំនួយសតិភាគទី ១១ ទំព័រ ១៤៣

២៥_ធម្មបទគាថា ចិត្តវគ្គទី ៣

បិដកលេខ ៥២ ទំព័រ ២៨

២៥_ព្រះភិក្ខុមួយអង្គនៅមាតិកគ្រាម

ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ទមថោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

ការទូន្មានចិត្តដែលសង្កត់សង្កិន បានដោយលំបាក ជាធម្មជាតិរហ័ស មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នា ក្នុងអារម្មណ៍ណាមួយ (ការទូន្មានចិត្តនុ៎ះ) រមែងជាគុណញាំងប្រយោជន៍ឱ្យសម្រេច (ព្រោះថា) ចិត្តដែលហ្វឹកហ្វឺន បានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

២៦_ព្រះភិក្ខុមួយអង្គដែលចង់សឹក

សុទុទ្ទសំ សុនិបុណំ យត្ថ កាមនិបាតិនំ
ចិត្តំ រក្ខេថ មេធាវី ចិត្តំ គុត្តំ សុខាវហំ ។

អ្នកមានប្រាជ្ញា គួររក្សាចិត្តដែលឃើញដោយកម្រក្រៃពេក ដែលល្អិតពេកណាស់ មានប្រក្រតីធ្លាក់ចុះទៅតាមសេចក្ដីប្រាថ្នាក្នុងអារម្មណ៍ណាមួយ (ព្រោះថា) ចិត្តដែលគេរក្សាបានហើយ រមែងនាំមកនូវសេចក្ដីសុខ ។

១៧_ជំនួយសតិភាគទី ១១ ទំព័រ ១៤៧

២៦_ធម្មបទគាថា បុប្ផវគ្គទី ៤

បិដកលេខ ៥២ ទំព័រ ៣០

៣៣_ព្រះភិក្ខុ ៥០០ អង្គ ខ្វល់ខ្វាយពីរឿងផែនដី

កោ ឥមំ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ
កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។
សេក្ខោ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ
សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។

អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំង

ទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះ ។

ព្រះសេក្ខបុគ្គល នឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះ ព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គល នឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការ ដែលឈ្លាសវៃជ្រើសរើសនូវផ្កាដូច្នោះឯង ។

៣៤.ព្រោះឃើញភិក្ខុមួយអង្គពិចារណាថ្ងៃបណ្តើរកូន

ផេណូបមំ កាយមិមំ វិទិត្វា
មរីចិធម្មំ អភិសម្ពុធានោ
ឆេត្វាន មារស្ស បបុប្ផកានិ
អទស្សនំ មច្ចុរាជស្ស គច្ឆេ ។

ភិក្ខុ កាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក ដឹងច្បាស់នូវកាយនេះថា មានសភាពដូចជាថ្ងៃបណ្តើរកូន គប្បីកាត់នូវកម្រងផ្កាជារបស់មារគឺវដ្ដៈ ៣ ទៅកាន់ស្ថានទី ដែលមច្ចុរាជមើលមិនឃើញ ។

១៨.ជំនួយសតិ ភាគទី ១១ ទំព័រ ១៥៥
២៧.ធម្មបទគាថា ពាលវគ្គទី ៥
បិដកលេខ ៥២ ទំព័រ ៣៤

---

៤៧.ព្រោះឃើញអានន្ទសេដ្ឋី ប្រដៅកូនឱ្យកំណាញ់

បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ
អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។

ជនពាលតែងព្រួយលំបាក ដោយសេចក្តីសំគាល់ថា កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន[៤] ចំណង់បើកូនទាំងឡាយនឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងសោបាកមាតា ។ បុត្រក្តី មាតាបិតាក្តី ញាតិក្តី ផៅពង្សក្តី កាលបើសេចក្តីស្លាប់មកដល់ រមែងមិនមានអ្នកណាពឹងពាក់បានឡើយ ។ ដោយឧបនិស្ស័យមានការស្តាប់ធម៌នេះហើយ នាងក៏បានសម្រេចជាព្រះសោតាបន្ន សោបាកៈមានអាយុត្រឹម ៧ ខួប បានសម្រេចព្រះអរហត្តផល បានអនុញ្ញាតពីព្រះមាន-ព្រះភាគឱ្យឧបសម្បទា ។

## ១៩_ខុទ្ទកនិកាយ ឧទាន ១០ ទំព័រ ១៨១
## បិដកលេខ ៥២ ទំព័រ ១២៦
## ពាហិយសូត្រ

សម័យមួយព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី។សម័យនោះឯង ពាហិយទារុចីរិយបុរស (អ្នកស្លៀកដណ្តប់សំពត់សម្បកឈើ ឈ្មោះពាហិយៈ) បានឃើញព្រះមានព្រះភាគ កំពុងនិមន្តបិណ្ឌបាត ក្នុងក្រុង

សោភិត ជាទីនាំមកនូវសេចក្តីជ្រះថ្លា គួរជ្រះថ្លា មានឥន្ទ្រិយស្ងប់ មានព្រះទ័យស្ងប់ ទ្រង់បានដល់នូវការហាត់ពត់ និងស្ងប់រម្ងាប់ដ៏ឧត្តម ទ្រង់បានទូន្មាន គ្រប់គ្រង សង្រួមឥន្ទ្រិយ ជាពុទ្ធនាគគឺជាព្រះពុទ្ធដ៏ប្រសើរ លុះឃើញព្រះមានព្រះភាគហើយក៏ឱនសិរ្សចុះទៀបព្រះបាទនៃព្រះមានព្រះភាគ ហើយអារាធនាព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ព្រោសខ្ញុំព្រះអង្គ សូមព្រះសុគត សម្តែងធម៌ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាអង្វែងដល់ខ្ញុំព្រះអង្គឱ្យបាន ។

កាលពាហិយទារុចីរិយបុរស អារាធនាយ៉ាងនេះហើយ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពាហិយទារុចីរិយបុរស ដូច្នេះថា ម្នាលពាហិយៈ ឈប់សិន កាលនេះជាកាលមិនគួរ ព្រោះតថាគតចូលទៅចន្លោះភូមិបិណ្ឌបាត។ ពាហិយ-ទារុចីរិយបុរស ទូលព្រះមានព្រះភាគ ជាគម្រប់ពីរដងយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរប្រព្រឹត្តទៅនៃជីវិតន្តរាយរបស់ព្រះមានព្រះភាគ ឬជីវិតន្តរាយរបស់ខ្ញុំ-

ព្រះអង្គ ដឹងបានដោយក្រណាស់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងធម៌ព្រោសខ្ញុំព្រះអង្គ សូមព្រះសុគតសម្តែងធម៌ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលជាអង្វែងដល់ខ្ញុំព្រះអង្គឱ្យទាន។ ពាហិយទារុចីរិយបុរស ទូលព្រះមានព្រះភាគ អស់វារៈ ៣ ដង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា តស្មាតិហ តេ ពាហិយ ឯវំ សិក្ខិតព្វំ ម្នាលពាហិយៈ ព្រោះហេតុនោះ អ្នកត្រូវសិក្សាយ៉ាងនេះថា ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតីតិ រូបារម្មណ៍ដែលឃើញហើយ គ្រាន់តែជារូបារម្មណ៍ដែលឃើញហើយ សទ្ទារម្មណ៍ដែលឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈរសៈផោដ្ឋព្វារម្មណ៍ ដែលប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ ដែលដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ដែលដឹងហើយ ឯវញ្ហិ តេ ពាហិយ សិក្ខិតព្វំ ម្នាលពាហិយៈ អ្នកគប្បីសិក្សាយ៉ាងនេះឯង ។

យតោ ខោ តេ ពាហិយ ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ សុតេ សុតមត្តំ ភវិស្សតិ មុតេ មុតមត្តំ ភវិស្សតិ វិញ្ញាតេ វិញ្ញាតមត្តំ ភវិស្សតិ ម្នាលពាហិយៈ ក្នុងកាលណា រូបារម្មណ៍ដែលអ្នកឃើញហើយ គ្រាន់តែជារូបារម្មណ៍ ដែលឃើញហើយ សទ្ទារម្មណ៍ដែលអ្នកឮហើយ គ្រាន់តែជាសទ្ទារម្មណ៍ដែលឮហើយ គន្ធៈរសៈផោដ្ឋព្វារម្មណ៍ដែលប៉ះពាល់ហើយ គ្រាន់តែជាអារម្មណ៍ដែលប៉ះពាល់ហើយ ធម្មារម្មណ៍ដែលអ្នកដឹងហើយ គ្រាន់តែជាធម្មារម្មណ៍ ដែលដឹងហើយ តតោ ត្វំ ពាហិយ នត្ថិ ម្នាលពាហិយៈ ក្នុងកាលនោះ អ្នករមែងមិនមាន យតោ ត្វំ ពាហិយ នេតត្ថ ម្នាលពាហិយៈ ក្នុងកាលណា អ្នករមែងមិនមាន តតោ ត្វំ ពាហិយ នេវិធ ន ហុរំ ន ឧភយមន្តរេ ម្នាលពាហិយៈ ក្នុងកាលនោះ អ្នករមែងមិនមានក្នុងលោកនេះ អ្នករមែងមិនមានក្នុងលោកខាងមុខ

អ្នករមែងមិនមានក្នុងចន្លោះនៃលោកទាំងពីរ ឯសេវន្តោ ទុក្ខស្សាតិ នេះឯងជាទីបំផុតនៃទុក្ខ ។

គ្រានោះ ចិត្តនៃពាហិយទារុចីរិយបុរសបានផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានឧបាទាន ក្នុងខណៈនោះឯង ដោយធម្មទេសនាសង្ខេបរបស់ព្រះមានព្រះភាគ ។

## ២០. ព្រះពុទ្ធវចនៈ

ធម្មោ ហវេ រក្ខតិ ធម្មចារឹ ៈ ធម៌រមែងរក្សានូវអ្នកប្រព្រឹត្តធម៌ ។

ន ទុគ្គតឹ គច្ឆតិ ធម្មចារី ៈ អ្នកប្រព្រឹត្តធម៌នឹងមិនទៅកាន់ទុគ្គតិ ។

ធម្មចារី សុខំ សេតិ ៈ អ្នកប្រព្រឹត្តធម៌ រមែងនៅជាសុខ ។

ធម្មោ សុចិណ្ណោ សុខមាវហាតិ ៈ ធម៌ដែលប្រព្រឹត្តល្អហើយ រមែងនាំសុខមកឲ្យ ។

សេចក្ដីសុខក្នុងទីនេះ គឺសុខព្រោះស្ងប់ សុខចិត្តព្រោះមានធម៌ជាទីពឹង សុខព្រោះអស់ទុក្ខ ។

## ២១. ជំនួយសតិភាគទី ៩ ទំព័រ ១៤

យោនិសោមនសិការ

បិដកលេខ ៤០ ទំព័រ ៣៦ និង ៣៧

ម្នាលភិក្ខុទាំងឡាយ តថាគតតំរិះរកមិនឃើញអង្គដទៃដែលជា អង្គខាងក្នុង សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំធេង ដូចជាយោនិសោមនសិការ[១] នេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានតែយោនិសោ-មនសិការនេះប៉ុណ្ណោះ ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំធេង ។

ម្នាលភិក្ខុទាំងឡាយ តថាគតតំរិះរកមិនឃើញអង្គដទៃដែលជា អង្គខាងក្រៅ សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ

[១] ការធ្វើទុកក្នុងចិត្ត ដោយឧបាយត្រូវទំនង ។

ដើម្បីប្រយោជន៍ដ៏ធំធេង ដូចជាការមាននូវកល្យាណមិត្ត នេះសោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ មានតែការមាននូវកល្យាណមិត្តនេះប៉ុណ្ណោះ ទើបប្រព្រឹត្តទៅដើម្បីប្រយោជន៍ដ៏ធំធេង ។

## ២២.ជំនួយសតិភាគទី ១០

### បិដកលេខ ៣៧ ទំព័រ ៦៣

### បឋមកល្យាណមិត្តសូត្រ

ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងថា " ការមានមិត្តល្អ ជាបុព្វនិមិត្តនៃអរិយមគ្គ " ។ សម័យមួយ ព្រះដ៏-មានព្រះភាគ ទ្រង់គង់នៅក្នុងសក្ករនិគមរបស់ពួកសក្យៈក្នុងដែនសក្យៈ ។ គ្រានោះ ព្រះសាស្តា ទ្រង់ត្រាស់នឹងអានន្ទថា ការមានមិត្តល្អ នេះជាប្រធាន នេះជាបុព្វនិមិត្ត ( គ្រឿងកំណាត់មុន ) ប្រព្រឹត្តទៅដើម្បីញ៉ាំងអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ឱ្យកើតឡើង ឱ្យចម្រើនឡើង ។

ម្នាលអានន្ទ ព្រោះអាស្រ័យតថាគត ដែលជាមិត្តល្អ បានជាពួកសត្វ ដែលមានជាតិជាធម្មតា រួចស្រឡះចាកជាតិទៅបាន ពួកសត្វដែលមានជរាជាធម្មតា រួចស្រឡះចាកជរាទៅបាន ពួកសត្វដែលមានមរណៈជាធម្មតា រួចមរណៈទៅបាន ពួកសត្វដែលមានការសោកខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តជាធម្មតា រួចស្រឡះចាកការសោកខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីចង្អៀតចង្អល់ចិត្តទៅបាន ។ ម្នាលអានន្ទ អ្នកគប្បីដឹងសេចក្តីនេះថា ជាព្រហ្មចរិយធម៌ទាំងមូលចុះ ។

លោកគ្រូជាម្ចាស់ បានសម្តែង ព្រះគាថារបស់ព្រះមានព្រះភាគ

សព្ភិរេវ សមាសេថ សព្ភិ កុព្វេថ សន្ថវំ
សតំ សទ្ធម្មមញ្ញាយ សព្វទុក្ខា បមុច្ចតិ ។

បុគ្គលគួរទាក់ទងជាមួយនឹងពួកសប្បុរសប៉ុណ្ណោះ គួរធ្វើសេចក្តីស្និទ្ធស្នាលដោយពួកសប្បុរស បុគ្គលដឹងព្រះសទ្ធម្មរបស់ពួកសប្បុរសហើយ រមែងរួចចាកទុក្ខទាំងអស់បាន ។

**អត្តា ហិ អត្តនោ នាថោ**

ខ្លួនហ្នឹងឯង ជាទីពឹងរបស់ខ្លួន ។

" ដូចបានរៀបរាប់ពីខាងដើមរួចមកហើយ "

ការមានខ្លួនឯងជាទីពឹងរបស់ខ្លួននេះ មានសេចក្ដីក្នុងប្រវត្តិរឿងរបស់ចូឡបន្ថកថេរ គប្បីសិក្សាបានជាបទពិចារណា ។ *ចូឡបន្ថកថេរ ( ចូឡបន្ថកភិក្ខុ )* ។

លោកគ្រូជាម្ចាស់ បានសម្ដែង ខ្ញុំបានស្ដាប់តាមរយៈខ្សែអាត់សំឡេងព្រះធម៌មានសេចក្ដីថា :

កាលសម័យព្រះសម្មាសម្ពុទ្ធ ទ្រង់គង់ព្រះជន្មនៅឡើយ មានពីរនាក់បងប្អូនជាភិក្ខុ មហាបន្ថកថេរជាបង ចូឡបន្ថកថេរជាប្អូន មហាបន្ថកៈជាអ្នកឆ្លាតឈ្លាស ឯចូឡ-បន្ថកៈល្ងង់ណាស់ រៀនធម៌១គាថា គឺ ៤បន្ទាត់ខំទន្ទេញអស់រយៈពេល ៤ខែនៅតែមិនចាំ ។ មហាបន្ថកៈ យល់ឃើញថាបើល្ងង់យ៉ាងនេះនៅបួសទៀតក៏ឥតប្រយោជន៍ ក៏បណ្ដេញឱ្យចេញពីវត្ត តែចូឡបន្ថកៈមិនព្រម ព្រោះមិនព្រាថ្នានឹងសឹក ។

គ្រាក្រោយមក កុមារពេទ្យឈ្មោះជីវកៈ បាននិមន្តព្រះសង្ឃក្នុងវត្តទាំងអស់ចំនួន ៥០០ អង្គ ទៅទទួលភត្តមហាបន្ថកៈ ជាភត្តុទ្ទេសក៍ បានចាត់ភិក្ខុទៅជាគម្រប់ ដោយមិនព្រមចាត់ចូឡបន្ថកៈឱ្យទៅ ដោយគិតថាល្ងិតល្ងង់ពេក ។ ឃើញមហាបន្ថកៈជាបងធ្វើដូចកាត់កាល់ដូច្នេះ ចូឡបន្ថក-ថេរ នឹកអន់ចិត្ត តូចចិត្តនឹងខ្លួនឯងដែលល្ងង់ពេក ក៏គិតថាមិនគួរនឹងនៅបួសតទៅទៀតទេ ទើបចាកចេញទៅ ។

គ្រានោះក៏បានជួបនឹងព្រះសម្មាសម្ពុទ្ធ ព្រះអង្គត្រាស់សួរព្រាបរឿងរ៉ាវសព្វគ្រប់ ទ្រង់ក៏ត្រាស់ហៅឱ្យត្រឡប់មកវិញ ។ ព្រះអង្គប្រទានសំពត់ស ១ ផ្ទាំងតូច ហើយទ្រង់ត្រាស់ថា ម្នាលចូឡបន្ថកៈ ចូរអ្នកយកដៃញីសំពត់នេះហើយការនាថា **រជោហរណំ** ឆាំចេញនូវធូលី ។ ចូឡបន្ថកៈ គ្រាដែលបាននូវសំពត់ហើយ ក៏ប្រារព្ធនូវសេចក្ដីព្យាយាម ធ្វើតាមព្រះឱវាទរបស់ព្រះសម្មាសម្ពុទ្ធ មិនយូរប៉ុន្មានសំពត់នោះក៏សៅហ្មង លោកក៏មាននូវសេចក្ដីត្រិះរិះថា ឱហ្ន៎ សំពត់នេះពីដើមស្អាតសោះ ឥឡូវប្រែទៅជាសៅហ្មង ឱ!

សង្ខារមិនទៀងទេហ្ន៎ ។ ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបថា ចូឡបន្ថកៈឃើញធម៌ ព្រះអង្គក៏ត្រាស់បន្ថែមទៀតថា សំពត់នេះគ្រាន់តែជូតធូលីខាងក្រៅ ម្នាលចូឡបន្ថកៈ ចូរអ្នកព្យាយាមជូតធូលីខាងក្នុង គឺ រាគៈ ទោសៈ មោហៈ ដែលជាអវិជ្ជាចេញឱ្យស្អាតផូរផង់ចុះ ។ លុះចប់ព្រះធម្មទេសនាដោយសង្ខេបនេះ ចូឡបន្ថកត្ថេរ ក៏បានសម្រេចអរហត្តផលព្រមទាំងបដិសម្ភិទា ។

## ២៣. ជំនួយសតិភាគទី ៩
## ទំព័រ ២០៣

សព្វាភិភូ សព្វវិទូហមស្មិ
សព្វេសុ ធម្មេសុ អនូបលិត្តោ
សព្វញ្ជហោ តណ្ហក្ខយេ វិមុត្តោ
សយំ អភិញ្ញាយ កមុទ្ទិសេយ្យំ ។

ជនណា អ្នកគ្របសង្កត់ធម៌ទាំងអស់ ដឹងនូវធម៌ទាំងអស់ មានប្រាជ្ញាល្អមិនជាប់ជំពាក់ក្នុងពពួកធម៌ទាំងអស់ លះបង់នូវធម៌ទាំងអស់ មានចិត្តចុះស៊ប់ក្នុងព្រះនិព្វានជាទីអស់ទៅនៃតណ្ហា ទើបតថាគតហៅជននោះថា អ្នកនៅតែម្នាក់ឯង ។

## ២៤. អដ្ឋកថា

បទថា សព្វាភិភូ ដោយសេចក្តីថា គ្របសង្កត់នូវខន្ធ អាយតនៈ ធាតុ និងភព ៣ ទាំងអស់ ។ បទថា សព្វវិទូ បានដល់ការដឹងច្បាស់នូវបញ្ចក្ខន្ធជាដើម ដែលមានប្រការដូចដែលបានពោលហើយទាំងអស់នោះ ។ បទថា សព្វេសុ ធម្មេសុ ដោយសេចក្តីថា គ្រឿងលាប គឺតណ្ហា និងទិដ្ឋិ មិនបានចូលទៅលាបហើយក្នុងធម៌ទាំងពួងនោះ ។ បទថា សព្វញ្ជហោ ដោយសេចក្តីថាលះបញ្ចក្ខន្ធនោះឯង ។ បទថា តណ្ហក្ខយេ វិមុត្តោ បានដល់ការបង្អោនទៅក្នុងព្រះនិព្វានដែលជាទីអស់ទៅនៃតណ្ហា ពោល គឺ វិមុត្តិដែលមានព្រះនិព្វានជាអារម្មណ៍ ។

( ទំព័រ ២០៤ ) ព្រះសម្មាសម្ពុទ្ធ ព្រះអង្គទ្រង់ត្រាស់ចែកបុគ្គល ចែកធម៌ ដើម្បីជាប្រយោជន៍ដល់ការជាក់ច្បាស់តាមសេចក្តីពិត ។ ដែលអាចចែកបុគ្គលទៅបាន ក៏ព្រោះអាស្រ័យមានសភាវធម៌ ដូច្នេះសភាវធម៌មិនមែនជាសត្វបុគ្គលឡើយ ហើយសត្វបុគ្គលក៏មិនមែនមាននៅក្រៅអំពីសភាវធម៌ទៀតដែរ នេះគឺជាបញ្ញត្តិអាស្រ័យបរមត្ថ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មានថា ដំណើរចេញចាកទុក្ខទៅតាមលំដាប់ គឺ ព្រះអង្គសម្តែងអំពីការរស់នៅដោយល្អគ្រប់គ្រងជីវិតដោយទាន ដោយសីល រួចហើយព្រះអង្គសម្តែងអំពីផលនៃការគ្រប់គ្រងជីវិតប្រកបដោយធម៌ល្អ ។

បុគ្គលដែលបានគ្រប់គ្រងជីវិតដោយធម៌ល្អរមែងមានសេចក្តីសុខអស់កាលយូរ ធម៌ដែលល្អហៅថាកល្យាណធម៌មាន ៥ យ៉ាងគឺ :

១ - មេត្តា ការគិតចង់ឱ្យអ្នកដទៃបានសុខរួចចាកទុក្ខ ។

២ - សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ ។

៣ - សទារសន្តោសៈ ការត្រេកអរចំពោះតែស្វាមីភរិយាខ្លួន ។

៤ - សច្ចៈ សេចក្តីពិត ( ការស្មោះត្រង់ ) ។

៥ - សតិ មានស្មារតីបរិបូណ៌ ។

## ២៥. បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌
### បិដកលេខ ២១ ទំព័រ ៨៧

បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ក្នុងព្រះពុទ្ធសាសនាគឺក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីសេចក្តីបរិសុទ្ធនៃសីលឬ? ដើម្បីសេចក្តីបរិសុទ្ធនៃចិត្តឬ? និងដើម្បីសេចក្តីបរិសុទ្ធនៃទិដ្ឋិឬ? ( សេចក្តីបរិសុទ្ធទាំង ៣ ក្នុងទីនេះបានដល់បញ្ញាកថាតែមួយប៉ុណ្ណោះ ) ។

បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងសំណាក់ព្រះមានព្រះភាគ ដើម្បីសេចក្តីបរិសុទ្ធនៃកង្ខាវិតរណៈឬ? ដើម្បីបរិសុទ្ធនៃមគ្គាមគ្គញ្ញាណទស្សនៈឬ? ដើម្បីបរិសុទ្ធនៃ

បដិបទាញាណទស្សនៈឬ? (បរិសុទ្ធទាំង៣ក្នុងទីនេះបានដល់បញ្ហាកថាតែមួយប៉ុណ្ណោះ) ។

បុគ្គលបានប្រព្រឹត្តព្រហ្មចរិយធម៌ សម្រេចនូវបញ្ហាកថាដូចបានពោលមកនេះ គឺដើម្បីបានដល់អនុបាទាបរិនិព្វាន ។ មិនមែនបានត្រឹមតែសីលបរិសុទ្ធ ជាដើមនោះទេ ។

## ២៦.ជំនួយសតិគាថាទី ១១

ទំព័រ ៦

សុចិណ្ណំ ព្រហ្មចរិយំ មេ មគ្គោ ចាបិ សុភាវិតោ
មរណេ មេ ភយំ នត្ថិ រោគានមិវ សង្ខយេ ។

ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គអាត្មាក៏បានចម្រើនល្អហើយ ភ័យចំពោះសេចក្តីស្លាប់នៃអាត្មាមិនមានទេ ដូចការមិនមានភ័យ ក្នុងកិរិយាអស់ទៅនៃរោគទាំងឡាយ ។

សុចិណ្ណំ ព្រហ្មចរិយំ មេ មគ្គោ ចាបិ សុភាវិតោ
និរស្សាទា ភវា ទិដ្ឋា វិសំ បិត្វាវ ឆឌ្ឌិតំ ។

ព្រហ្មចរិយធម៌ អាត្មាបានសន្សំល្អហើយ ទាំងមគ្គអាត្មាក៏បានចម្រើនល្អហើយ ភពទាំងឡាយដែលមិនមានសេចក្តីត្រេកអរអាត្មាក៏បានឃើញហើយ ដូចបុគ្គលផឹកនូវថ្នាំពិស ហើយខ្ជាក់ចោលវិញ ។

*" បិដកលេខ ២១ ទំព័រ ២១២ "*

ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា បុគ្គលណាឃើញបដិច្ចសមុប្បាទ (គឺសេចក្តីកើតឡើង ព្រោះអាស្រ័យហេតុ) បុគ្គលនោះឈ្មោះថាឃើញធម៌ បុគ្គលណាមួយឃើញធម៌ បុគ្គលនោះឈ្មោះថា ឃើញបដិច្ចសមុប្បាទ (គឺសេចក្តីកើតឡើង ព្រោះអាស្រ័យហេតុ) ។

*" បិដកលេខ ២១ ទំព័រ ២៥៤ "*

ព្រះមានព្រះភាគ ទ្រង់ត្រាស់ ព្រះសូត្រចំពោះបិង្គលកោច្ឆព្រាហ្មណ៍ ម្នាលព្រាហ្មណ៍ ព្រហ្មចរិយៈនេះមិនមែន

មានត្រឹមតែលាភសក្ការៈ និងសេចក្តីសរសើរជាអានិសង្សទេ មិនមែនមានត្រឹមតែសីលសម្បទាជាអានិសង្សទេ មិនមែនមានត្រឹមតែសមាធិសម្បទាជាអានិសង្សទេ មិនមែនមានត្រឹមតែញាណទស្សនៈជាអានិសង្សទេ ដោយប្រការដូច្នេះឯង ម្នាលព្រាហ្មណ៍ ចេតោវិមុត្តិ ការរួចចាកកិលេសនៃចិត្ត គឺអរហត្តផល ជាធម៌មិនកម្រើកណា ម្នាលព្រាហ្មណ៍ ព្រហ្មចរិយៈនេះ មានអរហត្តផលនុ៎ះជាប្រយោជន៍ មានអរហត្តផលនុ៎ះជាខ្លឹម មានអរហត្តផលនុ៎ះជាទីបំផុត ។

*" បិដកលេខ ១៨ អត្ថញ្ញសូត្រ "*

ពោលអំពីជាតិផ្សេងៗជាដើម ។ ដោយសារតែសេចក្តីប្រមាទចេះតែចម្រើន ពួកសត្វខ្លះក៏ចេះធ្វើនូវអំពើអាក្រក់ពួកសត្វខ្លះក៏ធ្វើល្អ ។ បុគ្គលខ្លះ អ្នកបានប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ជាសម្មាទិដ្ឋិប្រកាន់នូវកម្មជាសម្មាទិដ្ឋិលុះបែកធ្លាយរាងកាយ បន្ទាប់ពីស្លាប់ ក៏ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បុគ្គលខ្លះ ជាអ្នកធ្វើល្អខ្លះ អាក្រក់ខ្លះក្រោយពីស្លាប់ក៏បានទទួលសេចក្តីសុខខ្លះ ទុក្ខខ្លះ ។ បុគ្គលខ្លះ ជាអ្នកសង្រួមដោយ កាយ វាចា ចិត្ត ចម្រើនពោធិ-បក្ខិយធម៌ ៧ កង ( រាប់យកសតិប្បដ្ឋាន ៤ ជាកង១ រហូតដល់អដ្ឋង្គិកមគ្គជាកងទីបំផុត ) ក៏បរិនិព្វានក្នុងបច្ចុប្បន្ននេះឯង ។

២៧. ជ័យមង្គលគាថាទី ១១

គាថាព្រះអង្គុលិមាលត្ថេរ

បិដកលេខ ៥៧ ទំព័រ ៧២

ឆិន្នតណ្ហោ អនាទានោ គុត្តទ្វារោ សុសំវុតោ

អឃមូលំ វមិត្វាន បត្តោ មេ អាសវក្ខយោ ។

ខ្ញុំជាបុគ្គលប្រាសចាកតណ្ហា មិនមានសេចក្តីប្រកាន់ បានគ្រប់គ្រងទ្វារ សង្រួមដោយប្រពៃហើយ ការអស់ទៅនៃអាសវៈខ្ញុំបានដល់ហើយ ព្រោះបានសម្រាប់បួសគល់នៃទុក្ខ ។

សុខំ សយាមិ ឋាយាមិ សុខំ កប្បេមិ ជីវិតំ

អហត្ថបាសោ មារស្ស អហោ សត្ថានុកម្បិតោ ។

ឥឡូវនេះ ខ្ញុំដេកជាសុខ ឈរជាសុខ ចិញ្ចឹមជីវិត

ជាសុខ ជាបុគ្គលមិនទៅក្នុងអន្ទាក់នៃមារ និ! ព្រះសាស្តាទ្រង់អនុគ្រោះខ្ញុំ ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានគុណប្រមាណមិនបាន បុគ្គលអ្នកបានឃើញធម៌ ទើបបានដឹងថាព្រះតថាគត មានគុណដ៏ធំធេងចំពោះសត្វលោក ។ ព្រះតថាគត ទ្រង់មេត្តាចំពោះសត្វលោក ព្រះអង្គមានសេចក្តីព្យាយាម ខំបំពេញបារមីអស់រយៈពេល ៤ អសង្ខេយ្យ កម្រៃ ១ សែនកប្បដើម្បីបានត្រាស់ជាព្រះពុទ្ធ ហើយបានសម្រេចរូបមន្តដ៏វិសេស គឺព្រះធម៌មានចំនួន ៨៤,០០០ ព្រះធម្មក្ខន្ធ ។ ក្នុងកាលដែលព្រះតថាគតបានត្រាស់ដឹង ជាគ្រាដំបូង ព្រះអង្គព្រមទទួលការអារាធនារបស់ព្រហ្ម ក៏ព្រោះទ្រង់មានព្រះទ័យមេត្តា ករុណា ចំពោះសត្វទាំងឡាយ ទាំងពួង ។

គ្រានោះ ព្រះមានព្រះភាគទ្រង់បានពោលគាថា តបនឹងសហម្បតិព្រហ្មថា " ទ្វារនៃព្រះនិព្វាននោះ តថាគតបានបើកហើយ សត្វទាំងឡាយណា មានសោតប្បសាទ ចូរបញ្ចេញនូវសទ្ធាចុះ " ។

## ២៨. ចំរូស្ររបស់ព្រះតថាគត

ខ្ញុំបានស្តាប់បានអានមក ។ សម័យមួយ ព្រះមាន-ព្រះភាគ ទ្រង់និមន្តបិណ្ឌបាតបានជួបនឹងព្រាហ្មណ៍ ដែលជាកសិករ គឺ កសិភារទ្វាជព្រាហ្មណ៍ ក៏ពោលពាក្យចំពោះព្រះដ៏មានព្រះភាគថា បពិត្រសមណៈ ខ្ញុំព្រះអង្គរមែងភ្ជួរនិងសាបព្រោះ ហើយរមែងបានផលនោះទើបបរិភោគ ដូច្នេះសូមព្រះអង្គភ្ជួរ និងសាបព្រោះហើយបរិភោគចុះ ។

ព្រះដ៏មានព្រះភាគទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ តថាគតភ្ជួរ និងសាបព្រោះហើយ ទើបបរិភោគដូចអ្នកដែរ តែស្រែរបស់តថាគត មានសទ្ធាជាពូជ សេចក្តីព្យាយាមជាគៀង បញ្ញាជានឹមនិងនង្គ័ល ហិរិជាឃាមនង្គ័ល ចិត្តជាខ្សែ សតិជាផាល និងជន្លួញ ផលដែលច្រូតបាន គឺព្រះនិព្វាន បុគ្គលធ្វើស្រែយ៉ាងនេះហើយរមែងរួចផុតចាកទុក្ខទាំងពួង។

កសិភារទ្វាជព្រាហ្មណ៍មានសេចក្តីជ្រះថ្លា នឹងព្រះ-មានព្រះភាគយ៉ាងក្រៃលែង ទើបក្រាបបង្គំទូលព្រះអង្គថា

បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយ ដោយអនេកបរិយាយ ហាក់ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬក៏ដូចគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចគេប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោតដូចជាគេកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថាមនុស្សមានភ្នែកតែងមើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង ទីរលឹក ខ្ញុំព្រះអង្គសូមបាននូវបព្វជ្ជា សូមបាននូវឧបសម្បទាក្នុងសំណាក់នៃព្រះគោតមដ៏ចម្រើន ។

កសិភារទ្វាជព្រាហ្មណ៍ បានបព្វជ្ជាឧបសម្បទា ក្នុងសំណាក់នៃព្រះមានព្រះភាគ ។ ដោយមាននូវសេចក្តីព្យា-យាមជាអ្នកមិនប្រមាទ មានចិត្តស្ទុងទៅកាន់ ( ព្រះនិព្វាន ) ជាភិក្ខុម្នាក់ឯង ចេញចាកពួកគណៈ អស់កាលមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តផល ជាព្រះអរហន្តមួយអង្គ ក្នុងព្រះពុទ្ធសាសនា ។

ព្រះសម្មាសម្ពុទ្ធ ព្រះអង្គពិតជាបានត្រាស់ដឹងក្នុងលោក ។ ក្រោយពីបានត្រាស់ដឹង ព្រះអង្គទ្រង់សម្តែង **ធម្មចក្កប្បវត្តនសូត្រ** ដែលជាធម្មទេសនាដំបូង គឺក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ។ បន្ទាប់មកព្រះអង្គទ្រង់ព្យាយាមបំពេញនូវព្រះពុទ្ធកិច្ច ៤៥ព្រះវស្សា ។ វស្សាទី ៤៥ ជាវស្សាចុងក្រោយ ព្រះអង្គទ្រង់បរិនិព្វាន ក្នុងព្រះជន្មាយុ ៨០ វស្សា ។

ថ្ងៃដែលព្រះអង្គបរិនិព្វាន គឺនៅមុនពេលព្រះអង្គបរិនិព្វាន ព្រះអង្គទ្រង់ត្រាស់នឹងព្រះអានន្ទថា ម្នាលអានន្ទ បុគ្គលណា ដែលជាអ្នកបូជាតថាគត ដោយគ្រឿងសក្ការៈជាអាមិសបូជា(គឺការបូជាដោយផ្កាកម្រង ទៀនធូប ដោយវត្ថុ ) នេះជាការប្រសើរហើយ តែបរិស័ទទាំងឡាយណា ជាអ្នកប្រព្រឹត្តធម៌ ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌ ជាអ្នកប្រព្រឹត្តត្រូវនោះទើបឈ្មោះថា បានធ្វើសក្ការៈ បានធ្វើនូវសេចក្តីគោរព និងបានបូជាព្រះតថាគត ដោយធម្មបូជា ជា

## ២៩. ក្នុងសៀវភៅសុខចិត្ត និងគុណភាពនៃជីវិត

( ទំព័រ ៥៤ បព្វជិតល្អ )

ព្រះចន្ទខាងខ្នើតបង្កើតរស្មី ថ្ងៃពេញបូណ៌មីរាត្រីភ្លឺថ្លា
បព្វជិតព្យាយាមបំពេញសិក្ខា លម្អសាសនាដូចខែខាងខ្នើត។

### " អ្នកបួសមិនសង្រួមមិនល្អ "

បួសហើយគួរស្មោះចំពោះត្រង់ រក្សាវិន័យរបស់សង្ឃ
ដែលព្រះពុទ្ធអង្គក្រងសិក្ខា បួសហើយចិត្តឆេះកិលេសពេញ
បួសពិតតើបានប្រយោជន៍អ្វី ? អាប់ឱនសាសនាព្រះជិនស្រី
វិនាសដោយដែរអប្រិយជន ។
សន្សំបុណ្យណាស់ទើបបានត្រាស់ មាននាមជាព្រះឈ្នះអស់មារ
មិនបានគោរពបដិបត្តិបូជា សូមកុំផ្តន្ទាឱ្យវិនាស ។
បួសហើយកុំឱ្យគេថាបាន បើអ្នកណាហ៊ានមានអវិថី
ងចាំទទួលជាសាក្សី កាត់ទោសអប្រិយ៍ជនទ្រុស្តសីល ។

ព្រះពុទ្ធគ្រប់ៗព្រះអង្គ តែងតែទូន្មានប្រៀនប្រដៅ ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរព្យាយាមបំពេញនូវសេចក្តីល្អ ដែលជាប្រយោជន៍ចំពោះការរីកចម្រើននូវមហា-កុសល ។ ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយ ចូរកុំប្រមាទ គប្បីជាអ្នកមាននូវស្មារតី ចូររក្សាចិត្តរបស់ខ្លួនឱ្យបានល្អរឿយៗ ។ គប្បីជាអ្នកមានសីល និងរក្សានូវសីលឱ្យបានបរិសុទ្ធល្អ មានសមាធិ មាននូវបញ្ញា ។ ម្នាលអ្នកទាំងឡាយ បុគ្គលឯណា កាលបើមាននូវសេចក្តីព្យាយាម ព្រមទាំងបានប្រព្រឹត្តនូវធម៌ បដិបត្តិយ៉ាងត្រឹមត្រូវហើយ បុគ្គលនោះនឹងបានសម្រេចផល គឺជាទីបំផុតនូវទុក្ខ គោល គឺព្រះនិព្វាន ។ គួរជ្រះថ្លាក្នុងការបំពេញសេចក្តីល្អឱ្យបានច្រើនៗ ព្រោះកម្របានណាស់ នូវឱកាសពេលវេលានៃការបំពេញ សេចក្តីល្អ និងបានយល់ដឹងអំពីគុណប្រយោជន៍នៃអំពើល្អ ។

## ៣០. ស្រែបុណ្យ

ភាលវត្តសង្ឃារាមមហាធំធេង ធម្មជាតិតាក់តែងសព្វសត្វសង្ខារ
កើតចាស់ឈឺស្លាប់គ្រប់ៗគ្នា សង្ខារមិនទៀងត្រូវឱ្យសង្វេគ ។
ស្រណោះអ្នកខ្លះនៅក្រាស់ដោយកម្ម កិលេសដឹកនាំមិនឱ្យឃើញឆ្ងាយ
មានស្រែបុណ្យហើយព្រងើយមាក់ងាយ អនិច្ចានេះហើយព្រោះគ្មានទេសនា ។

លោកគ្រូអគ្គ ប៊ុត សាវង្សផាក់ បណ្ឌិតមហា
អ្នកប្រាជ្ញមានបុណ្យ ប្រោសធម៌ទេសនា ឱ្យយើងគ្រប់គ្នា
យល់ព្រះនិព្វាន ។

នេះហើយស្រែបុណ្យ ញាតិអើយកុំស៊ុន ខំបង្កើតផល
គ្រប់ជាតិមានកម្ម ព្រោះបុណ្យមិនដល់ វេលានៅសល់
សូមកុំប្រមាទ ។

ក្នុងនាមរូបខ្ញុំ ជីផ្ញើមួយសូម បង្គំថ្វា
សូមអង្គម្ចាស់គ្រូ លោកបានសុខជា យឺនយូរជន្មា
ទ្រទ្រង់សាសនា ។

*ដោយឧបាសិកា ខ៉ែន ស៊ីណា*

## ៣១. ព្រះពុទ្ធភាសិត ៤៣ គាថា

ទំព័រ ១២

អាជ្ញារបស់មច្ចុរាជ

យថា ទណ្ឌេន គោបាលោ
គាវោ បាជេតិ គោចរំ
ឯវំ ជរា ច មច្ចុ ច
អាយុំ បាជេន្តិ បាណិនំ ។

គង្វាលគោ កៀងគោទាំងឡាយ ទៅកាន់ទីគោចរ ដោយអាជ្ញា គឺដំបង ឬរំពាត់ យ៉ាងណាមិញ ជរា គឺសេចក្តីទ្រុឌទ្រោមគ្រាំគ្រា និងមច្ចុរាជ គឺសេចក្តីស្លាប់ ក៏កៀងទៅនូវអាយុរបស់សត្វទាំងឡាយក៏យ៉ាងនោះដែរ ។

ដូច្នេះអ្នកទាំងឡាយ គប្បីមានសេចក្តីព្យាយាមធ្វើបុណ្យក្នុងថ្ងៃនេះ ព្រោះមិនមានអ្នកណាអាចនឹងដឹងបានថា សេចក្តីស្លាប់នឹងមានចំពោះខ្លួនក្នុងថ្ងៃស្អែក ។

## ៣២_បណ្ដាំលោកគ្រូ

* កុំចង់បានរបស់ដែលអត់ កុំជាប់នឹងរបស់ដែលមាន អ្វីៗមានហេតុទើបកើតឡើង អ្វីណាដែលកើតឡើង អ្វីនោះជារបស់នៃសេចក្ដីប្រែប្រួលមានការវិនាសជាម្ចាស់ ។

* អ្នកដទៃធ្វើល្អមិនបាន ព្រោះមហាកុសលមិនបានកើតឡើង ឬព្រោះគេក្រសេចក្ដីល្អហ្នឹងឯង ។

* បើយើងស្អប់គេ ឈ្មោះថាស្អប់ខ្លួនឯងជាង ព្រោះយើងធ្វើអកុសលឱ្យខ្លួនឯង ។

* ចង់ល្អឱ្យលះ ចង់ឈ្នះឱ្យទ្រាំ ។

* បើមិនឈប់មិនជួបព្រះ បើមិនលះមិនជួបធម៌ ។ ខំលះលោភៈ ព្រោះតែងចង់បានរបស់ដែលអត់ មិនជាប់នឹងរបស់ដែលមាន ព្រោះជាទុក្ខ ។

* ព្រះសម្មាសម្ពុទ្ធទ្រង់បានសម្ដែងហើយថា ធម្មជាតិណាដែលមានការកើតឡើងជាធម្មតា ធម្មជាតិនោះ រមែង

* អ្នកដទៃធ្វើល្អមិនបាន គឺជារឿងរបស់គេ តែបើគេធ្វើអាក្រក់ យើងក៏គួរមេត្តា ព្រោះផលដែលបានអំពីសេចក្ដីអាក្រក់ គឺជាទុក្ខ ។

* គប្បីមានសេចក្ដីសន្ដោស ដើម្បីចម្រើននូវមហាកុសលឱ្យខ្លួនឯង ។ ចង់បានសេចក្ដីល្អ ត្រូវធ្វើដោយខ្លួនឯង អ្នកដទៃមិនអាចធ្វើជំនួសយើងបានឡើយ ។

* ស៊ូទ្រាំព្រោះចង់ឈ្នះ[១] សុខចិត្តលះ[២] ព្រោះចង់ល្អ ។

* ព្រមឈប់ព្រោះចង់ជួបព្រះ សុខចិត្តលះព្រោះចង់ជួបធម៌ ។

**អត្តនត្ថំ បរត្ថេន ពហុនាបិ ន ហាបយេ**

**អត្តនត្ថមភិញ្ញាយ សទត្ថបសុតោ សិយា ។**

បុគ្គលកុំគប្បីធ្វើប្រយោជន៍ខ្លួនឱ្យវិនាស ព្រោះប្រយោជន៍របស់អ្នកដទៃ សូម្បីច្រើនយ៉ាងណាក៏មិនមែនរបស់យើង គប្បីប្រឹងប្រែងធ្វើប្រយោជន៍របស់ខ្លួនឱ្យចម្រើន ។

## ៣៣. សុខចិត្ត និង គុណតម្លៃនៃជីវិត

ទំព័រ ៥០

❋ មនុស្សយើងត្រូវតែយល់ថា យើងបានល្អដោយសារ គេសរសើរក៏ទេ យើងទៅជាមនុស្សអាក្រក់ព្រោះគេតិះដៀលក៏ទេដែរ តាមសេចក្តីពិត យើងល្អព្រោះយើងបានធ្វើល្អ យើងអាក្រក់ព្រោះយើងធ្វើអាក្រក់ដោយខ្លួនឯង នេះជាច្បាប់របស់ហេតុផល ។

*" បិដកលេខ ១៦ ទំព័រ ២៨៦ "*

-ព្រះឧទានគាថា ។ បុណ្យ រមែងចម្រើនដល់អ្នកឲ្យទាន វេរាមិនចម្រើនដល់អ្នកសង្រួម បុគ្គលអ្នកឈ្លាស ( អ្នកបរិបូរណ៍ ដោយញាណ ) រមែងលះបង់នូវអំពើលាមក បាន បុគ្គលនោះក៏បរិនិព្វានព្រោះអស់ រាគៈ ទោសៈ មោហៈ ។

## ៣៤. បុគ្គលអ្នកស្ងប់

-បុគ្គល អ្នកដែលសម្លឹងសេចក្តីស្ងប់ គួរលះបង់នូវលោកាមិសទាំងឡាយចោលចេញ ។

**លោកាមិសំ បជហេ សន្តិបេក្ខោ**

**លោកាមិស** គឺ ជានុយរបស់លោក បានដល់អារម្មណ៍ ជាទីតាំងនៃតម្រេកផ្សេង ៗ ។

បុគ្គលអ្នកឃើញកាលឆ្ងាយ គួរហាត់លះបង់ម្តងបន្តិចៗ ជាការសាងនូវឧបនិស្ស័យល្អ និងអធ្យាស្រ័យល្អ ឲ្យខ្លួនឯង ។ ឧបនិស្ស័យនោះនឹងចាក់ឫសសន្សឹមៗ ចុះជ្រៅក្នុងសន្តានបានរឹងមាំមិនងាយនឹងទម្លាយឡើយ ។ ការយកចិត្តទុកដាក់ក្នុងការទំនុកបម្រុង និងការបរិច្ចាគលះបង់ក៏រីកផ្សាយសន្សឹមៗយ៉ាងទូលំទូលាយ ចេញទៅវេបុគ្គអាចធ្វើនូវអំពើដែលមនុស្សទាំងឡាយ ធ្វើបានដោយលំបាក ។ ដូចជាព្រះសម្មាសម្ពុទ្ធជាអង្គម្ចាស់ ព្រះអង្គទ្រង់លះបង់បានគ្រប់យ៉ាង ដើម្បីសេចក្តីល្អ និងសេចក្តីសុខរបស់សត្វលោក។

ឧដ្ឋានេនប្បមាទេន សញ្ញមេន ទមេន ច
ទីបំ កយិរាថ មេធាវី យំ ឱឃោ នាភិកីរតិ ។

អ្នកមានបញ្ញាគប្បីសាងកោះ គឺអរហត្តផល ជាកោះដែលជំនន់ គឺកិលេស ជន់លិចមិនបាន ដោយសេចក្តីមិនប្រមាទគឺការមិនប្រាសចាកនូវសតិផង ដោយសេចក្តីសង្រួមក្នុងចតុប្បារិសុទ្ធិសីលផង និងដោយការទូន្មាននូវឥន្ទ្រិយមានចក្ខុន្ទ្រិយជាដើមផង ។

## ៣៥. ជំនួយសតិភាគទី ១០

ទំព័រ១១

---

ក្នុងបិដកលេខ៥២ គម្ពីរឧទាន ១៥៤ **កាឡិគោធាភទ្ទិយសូត្រ** បានសម្តែងអំពី **ព្រះភទ្ទិយៈ** ដែលបានចេញពីសក្យត្រកូលមកបួស ហើយឧទានថា ឱហ្ន៎! សុខអ្វីម្ល៉េះ ។ សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងវត្តអម្ពវ័ន ទៀបក្រុងអនុប្បិយា ។ សម័យនោះ ព្រះភទ្ទិយៈដ៏មានអាយុ ជាបុត្រនាងសាកិយានី ឈ្មោះកាឡិគោធា ទោះនៅក្នុងព្រៃក្តី នៅទៀបគល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺនូវឧទានរឿយៗថា ឱហ្ន៎! សុខអ្វីម្ល៉េះ ។ ពួកភិក្ខុជាច្រើនរូបបានឮ ក៏ចូលគាល់ទូលព្រះមានព្រះភាគ ដោយមានសេចក្តីត្រិះរិះថា ព្រះភទ្ទិយៈ ប្រាកដជាអផ្សុកនឹងប្រព្រឹត្តព្រហ្មចរិយធម៌ដោយពិត ព្រះភទ្ទិយៈដ៏មានអាយុនេះ នឹករលឹកដល់សេចក្តីសុខក្នុងរាជ្យរបស់លោក កាលនៅជាគ្រហស្ថ ។

គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលភទ្ទិយៈ តថាគតបានឮថា អ្នកទោះនៅក្នុងព្រៃក្តី នៅទៀប គល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី តែងបន្លឺឧទានរឿយៗថា ឱហ្ន៎! សុខអ្វីម្ល៉េះៗ ដូច្នេះមែនឬ ។ ព្រះភទ្ទិយៈក្រាបទូលថា ព្រះករុណាព្រះអង្គ ។ ព្រះតថាគត ទ្រង់ត្រាស់ទៀតថា ម្នាលភទ្ទិយៈ តើអ្នកពិចារណាឃើញអំណាចប្រយោជន៍ដូចម្តេច ទើបពោលនូវឧទានដូច្នេះ។ ព្រះភទ្ទិយៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលពីដើម ខ្ញុំព្រះអង្គនៅជាគ្រហស្ថសោយសុខក្នុងរាជ្យ ការរក្សាខាងក្នុងព្រះរាជ

វាំង ខាងក្រៅព្រះរាជវាំង ខាងក្នុងព្រះនគរ ខាងក្រៅព្រះនគរ ទាំងក្នុងជនបទ និងខាងក្រៅជនបទ មានគេចាត់ចែងបានល្អហើយ ការរក្សាក៏ល្អហើយ តែខ្ញុំព្រះអង្គនេះឯងនៅតែភ័យភ្ញាក់ផ្អើលរង្កៀសពក់ស្លុត ។ បពិត្រព្រះអង្គ ដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គលះបង់អស់ហើយ ខ្ញុំព្រះអង្គនៅតែម្នាក់ឯង ចិញ្ចឹមជីវិតដោយបច្ច័យដែលអ្នកដទៃឱ្យ ជាការខ្វល់ខ្វាយតិច ក៏លែងភ័យ ភ្ញាក់ផ្អើល ព្រឺព្រួចរោមនៅដោយមានចិត្តដូចជាពួកម្រឹគ ។ បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពិចារណាឃើញអំណាចនៃប្រយោជន៍នេះ ទើបនៅទីណាក្តីតែងបន្លឺឧទានរឿយៗដូច្នេះ ។ ព្រះដ៏មាន-ព្រះភាគទ្រង់ជ្រាបច្បាស់សេចក្តីនេះហើយ ទើបទ្រង់បន្លឺព្រះឧទានថា :

សេចក្តីក្រោធ មិនមានក្នុងចិត្តបុគ្គលណា បុគ្គលនោះឈ្មោះថាកន្លងផុតនូវសេចក្តីចម្រើន និងសេចក្តីវិនាស ទេវតាទាំងឡាយ កម្រនឹងបានឃើញបុគ្គលដែលប្រាសចាកភ័យបាន ប្រកបដោយសេចក្តីសុខឥតសោកនោះឡើយ ។

បុគ្គល អ្នកសិក្សាបដិបត្តិព្រះធម៌ក្នុងព្រះពុទ្ធសាសនា គប្បីដឹងថាអ្វីៗទាំងអស់ក្នុងលោក គ្រាន់តែជាអារម្មណ៍របស់វិញ្ញាណប៉ុណ្ណោះ ឯវិញ្ញាណនោះបានដឹងនូវអារម្មណ៍ ហើយក៏រលត់ទៅ ។ អារម្មណ៍ដែលវិញ្ញាណបានដឹងជារបស់ខាងក្រៅ បើមិនប្រាថ្នានូវអារម្មណ៍នោះទេ កង្វល់ទាំងឡាយរមែងមិនមាន ស្ងប់ពិត ប្រណីតពិត នេះជាទីពឹងក្នុងវដ្តសង្សារ ជាទីពឹងដែលនាំឱ្យរួចផុតចាកទុក្ខទាំងពួង ។

គប្បីពិចារណាដល់របស់ដែលជាទីស្រឡាញ់ កាលពីថ្ងៃមុនបានបាត់បង់ និងប្រែប្រួលអស់ហើយ ឯរបស់ជាទីស្រឡាញ់ក្នុងថ្ងៃនេះក៏គង់នឹងប្រែប្រួលក្នុងថ្ងៃស្អែក ។

សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅជេតវនា-រាម ទ្រង់ប្រារព្ធបរាជ័យរបស់ព្រះបាទកោសល ។

ជយំ វេរំ បសវតិ ទុក្ខំ សេតិ បរាជិតោ
ឧបសន្តោ សុខំ សេតិ ហិត្វា ជយបរាជយំ ។

អ្នកឈ្នះរមែងជួបប្រទះនូវពៀរ អ្នកចាញ់តែងដេកជាទុក្ខ អ្នកដែលស្ងប់រម្ងាប់ លះបង់នូវការឈ្នះចាញ់បាន

ហើយ រមែងនៅជាសុខគ្រប់ឥរិយាបថទាំង ៤ ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបថាសេចក្តីសុខក្នុងលោក ជាសេចក្តីទុក្ខដោយពិត ជាសេចក្តីសុខដែលកៀងសត្វលោក ល្ងង់ខ្លៅឱ្យទៅព្រេកព្រអាល ។ កាលដែលព្រះអង្គមិនទាន់ចេញបួស ព្រះអង្គក៏ទ្រង់ធ្លាប់បានសោយនូវសុខនោះដែរ ។ ទើបក្រោយពេលដែលព្រះអង្គបានត្រាស់ដឹង ព្រះអង្គត្រាស់ថា : ព្រះនិព្វាន ទើបជាបរមសុខ ជាសេចក្តីពិត ។

(**និព្វានំ បរមំ សុខំ** ព្រះនិព្វានជា **បរមសុខ**)

## ៣៦-ជំនួយសតិគាថាទី ៩

អរុណពណ៌មាស យោនិសោមនសិការ

បិដកលេខ ៣៧ ទំព័រ ៦៤

ម្នាលភិក្ខុទាំងឡាយ ការរះឡើងនៃអរុណ នេះជាប្រធាន នេះជាបុព្វនិមិត្តនៃព្រះអាទិត្យដែលរះឡើង ។ ម្នាលភិក្ខុទាំងឡាយ ការបរិបូរណ៍ដោយយោនិសោមនសិការនេះ ជាប្រធាន នេះជាបុព្វនិមិត្តប្រព្រឹត្តទៅដើម្បីញុំាងអរិយមគ្គប្រកបដោយអង្គ ៨ ប្រការ ឱ្យកើតឡើង ដល់ភិក្ខុដោយប្រការនេះដែរ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរនេះជាទីសង្ឃឹមរបស់ភិក្ខុ ដែលបរិបូរណ៍ដោយយោនិសោមនសិការ ភិក្ខុនោះនឹងចម្រើនអរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការឱ្យច្រើនឡើង ។

## ៣៧-អរុណពណ៌មាស

អរុណពណ៌មាសជះរស្មី ផ្ដាំព្រាប់លោកិយថាលាហើយ
ឱ!ជនប្រុសស្រីទាំងឡាយអើយ នេះហើយសញ្ញាចំពោះអ្នក ។
អរុណរះរៀងមិនទៀងសុខ ព្រោះធម៌នាំមុខជាអនិច្ចំ
ជាធម៌នាំមកនូវទុក្ខខ្លាំង អនិច្ចំ ទុក្ខំ ជាអនត្តា ។
អនត្តាគឺមិនមែនខ្លួន ផ្ទួនៗព្រោះហេតុផលសង្ខារ
ធម៌នេះមានជាតិកើតទីណា មរណាតាមផ្តាច់មិនយល់មុខ។
សម្លឹងអរុណពិចារណា យល់ឃើញហេតុការចិត្តនឿយណាយ

លោភៈ ទោសៈ កាត់បង់យ ហោះហើយចេញ ៨ ជំរំទុក្ខ ។
លាទៅនិព្វានបរមសុខ រួចផុតចាកទុក្ខរស់កង្វល់
ទីដែលអ្នកប្រាជ្ញបានទៅដល់ តាល់ព្រះសាស្តាអង្គជិនស្រី ។

* ខំសង្រួមចិត្ត ចេះធម៌ពិតពិត
តែចិត្តរស់ខ្វល់ សង្ខារទាំងឡាយ
មានហេតុមានផល ប្រឹងចូលឱ្យដល់
ស្គាល់ព្រះនិព្វាន ។

*ដោយឧបាសិកា ទ៉ែង ស៊ីណា*

« នត្ថិ សន្តិ បរំ សុខំ »

ពុំមានសេចក្តីសុខដទៃក្រៅអំពីសេចក្តីស្ងប់ឡើយ ។

* ព្រះពុទ្ធ ប្រៀបដូចជា ផ្កាឈូកដែលរីក ។
* ព្រះធម៌ ប្រៀបដូចជា លម្អងកេសរដែលកើតក្នុងផ្កាឈូកនោះ ។
* ព្រះសង្ឃ ប្រៀបដូចជា ពួកភមរជាតិ ( មានឃ្មុំជាដើម ) ដែលត្រេបយកលម្អងកេសរក្នុងផ្កាឈូក ។

## ៣៨. សៀវភៅមនុស្សជាមួយនឹងការខេរ

ដកស្រង់ដោយសង្ខេប

---

អប្បមាទរតា ហោថ សចិត្តមនុរក្ខថ
ទុគ្គា ឧទ្ធរថត្តានំ បង្កេ សន្នោវ កុញ្ជរោ ។

អ្នកទាំងឡាយ ចូរត្រេកអរក្នុងសេចក្តីមិនប្រមាទ ចូរតាមរក្សាចិត្តរបស់ខ្លួន ចូរលើខ្លួនចាកភក់ គឺកិលេស ដែលគេឆ្លងបានដោយកម្រ ដូចដំរីជាប់ភក់ លើខ្លួនរួចបាន ។

* អប្បមាទេន អណ្ណវំ ឆ្លងមហាសមុទ្រ គឺសង្សារវដ្តបានដោយសេចក្តីមិនប្រមាទ ។

សទ្ទហានោ អរហតំ ធម្មំ និព្វានបត្តិយា
សុស្សូសំ លភតេ បញ្ញំ អប្បមត្តោ វិចក្ខណោ ។

បុគ្គល ជឿធម៌របស់ព្រះអរហន្តទាំងឡាយ ដើម្បីសម្រេចនូវព្រះនិព្វាន ជាអ្នកមិនប្រមាទ មានការពិចារណា ជាអ្នកស្តាប់ដោយល្អ រមែងបាននូវបញ្ញា ។

* បញ្ញាជីវី ជីវិតមាហុ សេដ្ឋំ បណ្ឌិតហៅ

ជីវិតដែលរស់នៅដោយបញ្ញាថា ជាជីវិតដ៏ប្រសើរ ។

## ៣៩.អានិសង្សនៃបុគ្គលមិនប្រមាទ

បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា
អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ
មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ
អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ បរមំ សុខន្តិ ។

ពួកជនពាលល្ងង់ខ្លៅ មិនមាននូវប្រាជ្ញាតែងប្រកបរឿយៗដោយសេចក្តីប្រមាទ គឺការធ្វេសប្រហែស អ្នកប្រាជ្ញរមែងរក្សាទុកនូវសេចក្តីមិនប្រមាទ ដូចរក្សាទ្រព្យដ៏ប្រសើរថ្លៃថ្លា អ្នកទាំងឡាយ ចូរកុំប្រកបរឿយៗ ដោយសេចក្តីប្រមាទ គឺការធ្វេសប្រហែសនេះឡើយ កុំគប្បីធ្វើសេចក្តីស្និទ្ធស្នាល ត្រេកត្រអាលក្នុងកាមទាំងឡាយឡើយ ព្រោះថាបុគ្គលអ្នកមិនមាននូវសេចក្តីប្រមាទ ខំសង្កេតពិនិត្យ រមែងបាននូវសេចក្តីសុខដ៏ឧត្តម ។

* ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងសង្ខារទាំងឡាយមានសេចក្តីសាបសូន្យជាធម្មតា ម្នាលអ្នកទាំងឡាយ ចូរញុំាងកិច្ចទាំងពួងឱ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ។ នេះជាបច្ឆិមវាចារបស់ព្រះតថាគត ។

* សុខោ វិវេកោ តុដ្ឋស្ស សុតធម្មស្ស បស្សតោ

សេចក្តីស្ងប់ស្ងាត់របស់អ្នកដែលត្រេកអរក្នុងទីស្ងាត់ ជាអ្នកមានធម៌បានស្តាប់ហើយ ពិចារណាឃើញធម៌ នាំមកនូវសេចក្តីសុខ ។

* យស្សេតេ ចតុរោ ធម្មា សទ្ធស្ស ឃរមេសិនោ សច្ចំ ធម្មោ ធិតិ ចាគោ ស វេ បេច្ច ន សោចតិ ។

បុគ្គលណាមានសទ្ធា ហើយជាអ្នកនៅគ្រប់គ្រងផ្ទះ ជាអ្នកមាននូវធម៌៤ ប្រការ គឺ សច្ចៈ ( ដែលនាំឱ្យមានកេរ្តិ៍-ឈ្មោះល្អ ឬការសរសើរ) ១ ធម្មៈ ( ការហ្វឹកហាត់អប់រំទូន្មានចិត្តដោយសទ្ធា ដោយសេចក្តីមិនប្រមាទ ដោយការពិចារណា និងដោយការស្តាប់ល្អ ជាធម៌នាំឱ្យមានបញ្ញា) ១ ធិតិ ( ព្យាយាមដោយអំណត់អត់ធន់ ប្រឹងប្រែងធ្វើការងារដ៏

សមគួរ ជាការងារព្រាសចាកនូវទោស ដើម្បីបាននូវទ្រព្យសម្បត្តិប្រកបដោយធម៌ ១ ចាគៈ ( សង្គហធម៌មានការបរិច្ចាគសម្បត្តិជួយអ្នកដទៃ ជាហេតុនៃការចងមិត្ត ) ១ បុគ្គលនោះឯង រមែងមិនមាននូវសេចក្តីសោកក្នុងលោកខាងមុខ ។

៙ ឯតំ ភយំ មរណេ បេក្ខមានោ លោកាមិសំ បជហេ សន្តិបេក្ខោ កាលបុគ្គលពិចារណាឃើញភ័យក្នុងសេចក្តីស្លាប់នៃជីវិតនេះ គប្បីសម្លឹងនូវសន្តិបទ គឺព្រះនិព្វាន ហើយលះបង់នូវគុយ គឺគ្រឿងជាប់ជំពាក់ក្នុងលោកចោល ឱ្យផុតស្រឡះ ។